### រៀបចំដោយ

នាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ
អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
ក្រសួងបរិស្ថាន

### ឧបត្ថម្ភដោយ

GEF / UNEP **តាមរយៈ:**
**គម្រោងបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទទន្រ្ទាន
រាតត្បាតលើវិស័យការពារ-អភិរក្ស និងផលិតកម្មព្រៃឈើ
ក្នុងតំបន់អាស៊ីអាគ្នេយ៍** (Cambodia FORIS Project)

យុទ្ធសាស្រ្តផ្សព្វផ្សាយជាតិសម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ



# យុទ្ធសាស្រ្តផ្សព្វផ្សាយជាតិ សម្រាប់ការគ្រប់គ្រងប្រភេទ ទន្រ្ទានរាតត្បាត

២០១៤

# អារម្ភកថា

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងក្រសួងបរិស្ថាន ខ្ញុំសូមសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកតវេទិតាដ៏ស្មោះត្រង់ចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រយ៉ាងពេញទំហឹង និងយកចិត្តទុកដាក់ខ្ពស់លើកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រង ប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប ដើម្បីលើកកម្ពស់គុណភាពបរិស្ថាន សុវត្ថិភាពប្រព័ន្ធអេកូឡូស៊ី និងសុខុមាលភាពសង្គម។ ការធ្វើពាណិជ្ជកម្ម និងការធ្វើដំណើរយ៉ាងឆាប់រហ័ស តាមរយៈមធ្យោបាយដឹកជញ្ជូននាសម័យទំនើប បានបណ្តាលឱ្យមានបំលាស់ប្តូរប្រភេទសត្វ និងប្រភេទរុក្ខជាតិ ពីផ្នែកមួយទៅផ្នែកមួយទៀតនៃភពផែនដី ទោះជាដោយចេតនាក្តី ឬអចេតនាក្តី ក៏នៅតែបង្កជាផលលំបាកណាមួយដែលមិនអាចនឹកស្មានដល់។ បច្ចុប្បន្ននេះ ប្រភេទទន្រ្ទានរាតត្បាត ត្រូវបានគេចាត់ទុកថា ជាប្រភេទមួយក្នុងចំណោមប្រភេទកំពុងគម្រាមកំហែងដល់ធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ។ ម៉្យាងវិញទៀត ប្រភេទទន្រ្ទានរាតត្បាត ក៏ផ្តល់នូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរ ដល់វិស័យកសិកម្ម ព្រៃឈើមច្ឆជាតិ និងសុខភាពមនុស្ស។

តាមរយៈការសិក្សានាពេលថ្មីៗបានឱ្យដឹងថា នៅតំបន់អាស៊ីអាគ្នេយ៍ កើតមាននូវការខាតបង់ថវិកាជាប្រចាំឆ្នាំសរុបចំនួន៣៣៥០០លានដុល្លាអាមេរិក ដែលបណ្តាលមកពីប្រភេទទន្រ្ទានរាតត្បាតទៅលើវិស័យកសិកម្ម សុខភាពមនុស្ស និងបរិស្ថាន ដែលក្នុងនោះប្រហែលជា ៩០% ខាតបង់ទៅលើវិស័យកសិកម្ម និងព្រៃឈើ ហើយផ្នែកដែលនៅសល់ខាតបង់ទាក់ទងទៅនឹងសុខភាពមនុស្ស និងបរិស្ថាន។ នៅឆ្នាំ២០១៥ ប្រទេសទាំងឡាយក្នុងតំបន់ ត្រូវបានគេរំពឹងថានឹងសម្រេចបាននូវគោលដៅសហគមន៍ទីផ្សារអាស៊ាន ដែលអនុញ្ញាតឱ្យមានប្រព័ន្ធទីផ្សារសេរី សម្រាប់ការនាំចេញ នាំចូលផលិតផលជីវសាស្ត្រ(Biological products)កាន់តែច្រើន។ ប្រព័ន្ធទីផ្សារសេរីនេះ ត្រូវបានគេប្រមើលឃើញថា នឹងបង្កើនបញ្ហាដែលពាក់ព័ន្ធជាមួយប្រភេទទន្រ្ទានរាតត្បាតកាន់តែច្រើនឡើងៗ ហើយពិភពលោកក៏កំពុងតែយកចិត្តទុកដាក់ និងទាមទារឱ្យប្រទេសជាសមាជិកត្រូវមានចំណាត់ការ ដើម្បីគ្រប់គ្រងការរីករាលដាលប្រភេទទន្រ្ទានរាតត្បាត ដូចបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគោលដៅជីវៈចម្រុះ Aichi នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ(CBD)។ នៅឆ្នាំ២០២០ អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ សង្ឃឹមថាប្រភេទរាតត្បាត និងលំហូររបស់វា ត្រូវបានគេកំណត់អត្តសញ្ញាណ និងអាទិភាពរីឯប្រភេទអាទិភាពដែលបានកំណត់ ត្រូវបានគេគ្រប់គ្រង ឬកំចាត់ និងចាត់វិធានការនៅនឹងកន្លែង ដើម្បីគ្រប់គ្រងលំហូរ សម្រាប់បង្ការនូវការហូរចូល និងតាំងទីលំនៅក្នុងប្រទេសណាមួយ។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជា បានរៀបចំនូវគោលដៅ និងសូចនាករជីវៈចម្រុះជាតិ ដោយបានដាក់បញ្ចូលបញ្ហាប្រភេទទន្រ្ទានរាតត្បាតនេះ ជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ។

ដោយសារសមត្ថភាព និងការយល់ដឹង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីប្រភេទទន្រ្ទានរាតត្បាតនៅមានកម្រិតកំណត់ ទើបក្រសួងបរិស្ថាន រៀបចំបង្កើតសៀវភៅ "**យុទ្ធសាស្ត្រផ្សព្វផ្សាយជាតិសម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត**" ឡើង ក្នុងគោលបំណងលើកឡើងជាអនុសាសន៍អំពីវិធីដ៏ប្រសើរបំផុត ដើម្បីផ្សព្វផ្សាយ និងកែប្រែឥរិយាបថ ដែលទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត ក្នុងចំណោមសាធារណជនទូទៅ និងក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ ឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់វា។ ការបញ្ជ្រាបការយល់ដឹងទាក់ទងទៅនឹងផលប៉ះពាល់របស់ប្រភេទទន្រ្ទានរាតត្បាត និងវិធីសាស្ត្រកំចាត់សមស្រប ជាវិធានការចាំបាច់

ក្នុងការទប់ស្កាត់ និងកំចាត់ប្រភេទនេះ។ ការងារនេះទាមទារឱ្យមានការចូលរួមពីគ្រប់ស្ថាប័នរដ្ឋាភិបាល វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងប្រជាសហគមន៍ផ្ទាល់ ទើបអាចសម្រេចជាផ្លែផ្កាបានពេញលេញ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ស្ថាប័នជំនាញការទាំងអស់ ដែលបានផ្តល់ និងគាំទ្រទាំងធនធានបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងការរៀបចំ **យុទ្ធសាស្ត្រផ្សព្វផ្សាយជាតិសម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត** ដែលជាចំណុចចាប់ផ្តើមដំបូងបំផុតសម្រាប់ការរួមចំណែកលើកកម្ពស់ការយល់ដឹង បង្កើនការចាប់អារម្មណ៍ និងជំរុញឱ្យមានការកែប្រែឥរិយាបថរបស់សាធារណជនទូទៅ និងក្រុមអ្នកពាក់ព័ន្ធនានា ដែលជាបច្ច័យឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់ប្រភេទទន្រ្ទានរាតត្បាតបាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

សាយ សំអាល់

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ និងក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិកសមាជិការ នៃអនុគណៈកម្មាធិការបច្ចេកទេសជាតិគ្រប់គ្រងជីវៈចម្រុះ និងឯកឧត្តម លោកជំទាវ ជាសមាជិកសមាជិការ នៃគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ ដែលបានចូលរួមយ៉ាងសកម្ម និងផុសផុលក្នុងការផ្តល់មតិយោបល់ កែលម្អ និងណែនាំដ៏មានតម្លៃ ក្នុងការរៀបចំ **យុទ្ធសាស្ត្រផ្សព្វផ្សាយជាតិ សម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត** នេះឡើង តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ និងកិច្ចប្រជុំគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចម្រុះ កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១៤។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិទាំងអស់ (សហភាពអន្តរជាតិដើម្បី អភិរក្សធម្មជាតិ អង្គការជីវិតសត្វស្លាបអន្តរជាតិ មូលនិធិសត្វព្រៃពិភពលោក សមាគមអភិរក្សសត្វព្រៃ អប់រំស្តីពីការរស់នៅជាមួយបរិស្ថាន) អ្នកផ្តល់បាឋកថា និងនិស្សិត នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យបញ្ញាសាស្ត្រ រួមជាមួយប្រជាពលរដ្ឋ ក្នុងសហគមន៍នៅ ចុងឃ្នាស តំបន់ស្នូលព្រែកទ័ល និងតំបន់ស្នូលស្ទឹងសែន ដែលបានចែករម្លែកព័ត៌មាន និងបទពិសោធន៍ផ្ទាល់ខ្លួន ក្នុងការរួមចំណែករៀបចំឯកសារយុទ្ធសាស្ត្រផ្សព្វផ្សាយនេះ។ ការចូលរួមយ៉ាងទូលំទូលាយរបស់អ្នកពាក់ព័ន្ធនានា បានធ្វើឱ្យយុទ្ធសាស្ត្រផ្សព្វផ្សាយជាតិ សម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាតនេះកាន់តែមានសង្គតិភាព និងមានការគាំទ្រយ៉ាងទូលំទូលាយពីគ្រប់វិស័យទាំងអស់។

**យុទ្ធសាស្ត្រផ្សព្វផ្សាយជាតិ សម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត** ត្រូវបានរៀបចំឡើងដោយអ្នកជំនាញការជាតិ ក្រោមការជួយសម្របសម្រួលពីនាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងដោយមានការជួយឧបត្ថម្ភថវិកាពី UNEP/GEF តាមរយៈគម្រោងបំបាត់ភាពរាំងស្ទះដល់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត លើវិស័យការពារ-អភិរក្ស និងផលិតកម្មព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍ (FORIS)។

# មាតិកាអត្ថបទ


អារម្ភកថា ..... i
សេចក្ដីថ្លែងអំណរគុណ ..... iii
មាតិកាអត្ថបទ ..... iv
ពាក្យបំព្រួញ ..... v
សេចក្ដីសង្ខេបប្រតិបត្តិ ..... 1
ប្រវត្តិដើម ..... 2
គោលបំណងនៃឯកសារនេះ ..... 3
អតិក្រមជាយុទ្ធសាស្ត្រ ..... 4
ការផ្សព្វផ្សាយទូលំទូលាយ ..... 5
ការផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ ..... 5
ការផ្សព្វផ្សាយជាមួយសាធារណជន ..... 6
ការបណ្ដុះបណ្ដាល និងការអប់រំ ..... 7
ផលប្រយោជន៍ និងឧបសគ្គ ..... 8
ឧបសម្ព័ន្ធ I ..... 18
ឯកសារយោង ..... 24

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CBD | Convention on Biological Diversity | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| EU | European Union | សហភាពអឺរ៉ុប |
| GEF | Global Environment Facility | មូលនិធិបរិស្ថានពិភពលោក |
| IAS | Invasive Alien Species | ប្រភេទទន្រ្ទានរាតត្បាត |
| IUCN | International Union for Conservation of Nature | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| INGO | International Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| IO | International Organization | អង្គការអន្តរជាតិ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RUA | Royal University of Agriculture | សកលវិទ្យាល័យភូមិន្ទកសិកម្ម |
| UNEP | United Nation Environment Program | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| WB | World Bank | ធនាគារពិភពលោក |
| WCS | Wildlife Conservation Society | សមាគមអភិរក្សសត្វព្រៃ |
| WWF | World Wild Fund | មូលនិធិសត្វព្រៃពិភពលោក |

# សេចក្តីសង្ខេបប្រតិបត្តិ

ប្រភេទ(សត្វ ឬរុក្ខជាតិ)ទន្ទ្រានរាតត្បាត(IAS) ត្រូវបានចាត់ទុកជាមូលហេតុចំបងមួយនៃការបាត់បង់ជីវៈចម្រុះ ហើយកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន ដែលរួមទាំងអនុសញ្ញាស្តីពីជីវៈចម្រុះ(CBD) ក៏តម្រូវឱ្យមានចំណាត់ការ ដើម្បីដោះស្រាយការគំរាមកំហែង ដែលបង្កដោយប្រភេទទាំងនោះដែរ។បញ្ហានានា ដែលបង្កដោយប្រភេទទន្ទ្រានរាតត្បាត កំពុងតែមានសភាពកាន់តែធ្ងន់ធ្ងរឡើងៗ នៅពេលដែលប្រជាជនមានបម្លាស់ទី និងទំនិញកាន់តែឡើងថ្លៃ។ ការប្រែប្រួលអាកាសធាតុទំនងជាធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរជាខ្លាំង។ អ្នកស្រាវជ្រាវ និងទីភ្នាក់ងារបរិស្ថានអន្តរជាតិមួយចំនួន បានទទួលស្គាល់ជាទូទៅ អំពីការបង្កើនការយល់ដឹងទៅលើប្រភេទទន្ទ្រានរាតត្បាត និងបញ្ហាដែលបង្កឡើងដោយប្រភេទទាំងនោះ។ ក៏ប៉ុន្តែក្នុងសាធារណជនទូទៅ និងមន្ត្រីរដ្ឋាភិបាលនានាជុំវិញពិភពលោក ពួកគេស្ទើរតែពុំមាន ឬមានការយល់ដឹង និងចំណេះដឹងតិចតួចប៉ុណ្ណោះ អំពីការគំរាមកំហែងដែលបង្កដោយប្រភេទទន្ទ្រានរាតត្បាត។

ប្រភេទទន្ទ្រានរាតត្បាត ពុំទាន់ត្រូវបានចាត់ជាអាទិភាពនៅឡើយទេ នៅក្នុងរបៀបវារៈនៃការអភិរក្ស។ ទោះជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិខ្លះ និងសហគមន៍មូលដ្ឋាន បានចាត់វិធានការដាច់ដោយឡែកតែរៀងៗខ្លួន ដើម្បីទប់ស្កាត់ប្រភេទទន្ទ្រានរាតត្បាត ដែលបង្កការប៉ះពាល់មកលើកសិផល និងបរចិញ្ចឹមជីវិតរបស់ពួកគេ។ ចំណាត់ការរបស់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន សហគមន៍ និងដៃគូអភិរក្ស បានធ្វើឡើងជាលក្ខណៈបណ្តោះអាសន្ន មិនបានធ្វើជាលក្ខណៈប្រព័ន្ធទេ ហើយក៏ពុំមានការធានាអំពីនិរន្តរភាពឡើយ។ជាក់ស្តែងអង្គការជីវិតសត្វស្លាបអន្តរជាតិបានសាកល្បងគម្រោងកំចាត់"ដើមក្លបយក្ស"ហើយអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានមួយចំនួន បានព្យាយាមបំលែងប្រភេទទន្ទ្រានរាតត្បាត ឱ្យមានអត្ថប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច ដូចជាធ្យូងផលិតចេញពីដើមក្លបយក្ស និងផលិតផលដទៃទៀត ដែលផលិតចេញពីប្រភេទទន្ទ្រានរាតត្បាត។ ក៏ប៉ុន្តែគ្មានគម្រោងណាមួយ អាចបង្ហាញពីជោគជ័យ និងនិរន្តរភាព ជាដុំកំភួនឡើយ។

នេះក៏ដោយសារអវត្តមានគោលនយោបាយ និងច្បាប់ស្តីពីប្រភេទទន្ទ្រានរាតត្បាត ឬសមត្ថភាព និងការយល់ដឹង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីប្រភេទទន្ទ្រានរាតត្បាតនៅមានកម្រិត។

មានការសន្មតិថាការយល់ដឹង និងចំណេះដឹងអំពីបញ្ហាប្រភេទទន្ទ្រានរាតត្បាត នៅមានកម្រិតទាប ក្នុងចំណោមសាធារណជនទូទៅ។ អំណះអំណាងនេះមានភាពស្របគ្នាជាមួយការសិក្សាមួយអំពី "ជីវៈចម្រុះ និងកម្រិតសេដ្ឋកិច្ច-សង្គម នៅមុនអន្តរាគមន៍នៅថ្នាក់ជាតិ លើការគ្រប់គ្រងដើមក្លបយក្ស" នៅក្នុងទីតាំងសាកល្បងតំបន់ស្នួលស្ទឹងសែន និងការសិក្សាវាយតម្លៃឆាប់រហ័សមួយអំពីឥរិយាបថ និងអាកប្បកិរិយារបស់សាធារណជនចំពោះប្រភេទទន្ទ្រានរាតត្បាត ជាពិសេសដើមក្លបយក្សនៅកម្ពុជា។ សេចក្តីសង្ខេបមួយអំពីលទ្ធផលនៃការវាយតម្លៃនេះ មានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ ១។

ការវាយតម្លៃនេះ នឹងជួយដល់ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយជាតិសម្រាប់ការគ្រប់គ្រងប្រភេទទន្ទ្រានរាតត្បាត និងផ្តល់ជាព័ត៌មានដើម ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យតាមដានផែនការយុទ្ធសាស្ត្រនេះ។ ទោះបីខ្វះការយល់ដឹងក៏ដោយ ការវាយតម្លៃនេះបានបង្ហាញអំពីតម្រូវការជាខ្លាំងនូវព័ត៌មានអំពីប្រភេទទន្ទ្រានរាតត្បាត។

# ប្រវត្តិដើម

ប្រភេទ(សត្វ ឬរុក្ខជាតិ)ទន្រ្ទានរាតត្បាត(IAS) គឺជាសារពាង្គកាយអន្តោគ្រាមដែលបង្ក ឬមានលទ្ធភាពក្នុងការបង្កគ្រោះថ្នាក់មកលើបរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច កសិកម្ម ឬសុខភាពមនុស្ស និងសត្វ។ ប្រភេទទាំងនេះគឺជាមូលហេតុចំបងបំផុតមួយ ក្នុងចំណោមមូលហេតុនានាដែលបង្កឱ្យមានការប្រែប្រួលបរិស្ថាននៅទូទាំងពិភពលោក ដែលជាលទ្ធផល បានបង្កជាឧបសគ្គចំពោះការអភិរក្សបរិស្ថាន កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍដោយចីរភាព។ ពាណិជ្ជកម្ម ការធ្វើដំណើរ និងការដឹកជញ្ជូន បានបង្កើនជាខ្លាំងនូវអត្រានៃការរាលដាលប្រភេទទាំងនេះនៅជុំវិញពិភពលោក។ ទន្ទឹមនឹងនេះ ការប្រែប្រួលលើការប្រើប្រាស់ដី និងការប្រែប្រួលអាកាសធាតុ កំពុងធ្វើឱ្យទីជម្រកខ្លះ កាន់តែងាយស្ថិតក្រោមឥទ្ធិពលនៃការរាតត្បាតខាងជីវសាស្ត្រ។[1]

ប្រភេទទន្រ្ទានរាតត្បាត គឺជាកត្តាគំរាមកំហែងធំជាងគេទីពីរចំពោះជីវៈចម្រុះ បន្ទាប់ពីទីជម្រកត្រូវបានបំផ្លាញ។ នៅកម្ពុជា ប្រភេទទន្រ្ទានរាតត្បាត កំពុងមានឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងមកលើជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី នៅតាមមូលដ្ឋាន និងនៅកម្រិតជាតិ ហើយវាក៏កំពុងតែរាតត្បាត និងគំរាមកំហែងមកលើទីជម្រកប្រភេទ(សត្វ និងរុក្ខជាតិ) និងសមត្ថភាពផលិតនៃប្រភេទទាំងនោះ ក៏ដូចជា ឥទ្ធិពលដោយប្រយោល មកលើបេះចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើព្រៃឈើសម្រាប់សន្តិសុខស្បៀង ផលិតផល និងសន្តិសុខថាមពលផងដែរ។ ប្រភេទទន្រ្ទានរាតត្បាត ជាពិសេស *ដើមក្របយក្ស គឺជាកត្តាគំរាមកំហែងចំបងមួយចំពោះជីវៈចម្រុះ ក្នុងដែនសមុទ្រ ដែនទឹកសាប និងដែនដីគោក។*

មាត្រា ៨(h) នៃអនុសញ្ញាស្តីពីជីវៈចម្រុះ (CBD) អំពាវនាវដល់ប្រទេសជាសមាជិកឱ្យ"ធ្វើការទប់ស្កាត់ការនាំចូល ដាក់កំហិត ឬលុបបំបាត់ ប្រភេទទន្រ្ទានរាតត្បាតទាំងនោះតាមតែអាចធ្វើបាន ដើម្បីជៀសវាងការគំរាមកំហែងនៃប្រភេទទាំងនេះមកលើប្រព័ន្ធអេកូឡូស៊ី ទីជម្រក និងប្រភេទ(សត្វ និងរុក្ខជាតិ)នានា"។ ទោះជាយ៉ាងណាក៏ដោយ វិធានការឆ្លើយតបនៅកម្រិតជាតិ និងអន្តរជាតិចំពោះបញ្ហាប្រភេទទន្រ្ទានរាតត្បាតរហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់គ្រប់គ្រាន់ដើម្បីប្រឆាំងតបនឹងការគំរាមកំហែងកាន់តែខ្លាំងឡើងនៃប្រភេទទាំងនេះមកលើធនធានធម្មជាតិ និងសង្គមនៅឡើយទេ។ ឧបសគ្គសំខាន់បំផុតមួយចំពោះការកសាងគោលនយោបាយ និងការអនុវត្ត គឺកង្វះការយល់ដឹងអំពីផលវិបាកនៃការរាតត្បាតខាងជីវសាស្ត្រទាំងនេះ។

### *ស្ថានភាពបច្ចុប្បន្ន*

ប្រភេទទន្រ្ទានរាតត្បាត ដែលគំរាមកំហែងដល់ជីវៈចម្រុះនៅកម្ពុជាត្រូវបាននាំចូលកាន់តែច្រើនឡើងតាមរយៈពាណិជ្ជកម្ម ការធ្វើដំណើរ និងការដឹកជញ្ជូន។ នៅកម្ពុជា មានការនាំចូលរុក្ខជាតិកាន់តែច្រើនឡើងសម្រាប់គោលបំណងកសិកម្ម វារីវប្បកម្ម និងសម្រាប់បម្រើភាពជាទីគាប់ចិត្ត។ ដូច្នេះ ការនាំចូលប្រភេទទន្រ្ទានរាតត្បាត មកពីខាងក្រៅប្រទេសកម្ពុជាដោយសារសកម្មភាពសេដ្ឋកិច្ច បានបង្កការប៉ះពាល់ធ្ងន់ធ្ងរដល់ប្រភេទពូជក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ បន្ថែមលើកត្តានៃការរាលដាលជាខ្លាំងនៃប្រភេទទន្រ្ទានរាតត្បាត គឺការបំលែងព្រៃធម្មជាតិជាទ្រង់ទ្រាយធំសម្រាប់គោលបំណងនៃការប្រើប្រាស់ផ្សេងៗ។ កម្ពុជាបានបាត់បង់ ២២%(២,៨លានហិចតា)នៃគម្របព្រៃឈើរបស់ខ្លួននៅរវាងឆ្នាំ ១៩៩០ និង ២០១០[2] ហើយប្រការនេះបាននាំឱ្យមានកំណើនប្រភេទទន្រ្ទានរាតត្បាត នៅលើដីព្រៃឈើរេចរឹលជាខ្លាំង។

---

[1] Prevention and Management if Invasive Alien Species (2002)
[2] Project document "Removing Barriers to Invasive Species Management in Production and Protection (p.15)

ការវាយតម្លៃដែលបានធ្វើឡើងដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន បានបង្ហាញអំពីពពួកទន្រ្ទានរាតត្បាតចំនួន ៦៧ប្រភេទ ដែលបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសកម្ពុជា។ ពពួកប្រភេទរាតត្បាតទាំងនេះមានជាអាទិ៍ រុក្ខជាតិ[3] ២៦ប្រភេទ ត្រី[4] ៣១ប្រភេទ សត្វល្អិត៣ប្រភេទ ល្មូន ៣ប្រភេទ ថលជលិក ៣ប្រភេទ និងថនិកសត្វ[5] ១ប្រភេទ។

ការនាំចូលប្រភេទទន្រ្ទានរាតត្បាតពីប្រទេសដទៃមកប្រទេសកម្ពុជា ឬប្រទេសជិតខាង កំពុងរាលដាលហួសព្រំដែនប្រទេស ដោយសារការចល័តតាមលក្ខណៈធម្មជាតិ រួមមាន ខ្យល់ ទឹក និងសត្វ ដែលជាភ្នាក់ងារចម្លង។ ឧទាហរណ៍ ដើមក្លបយក្ស ដែលត្រូវបានគេស្គាល់ថាជា បន្លាក្លបយក្ស មានប្រភពពីតំបន់ត្រូពិកភាគខាងត្បូង និងអាមេរិកកណ្តាល ប៉ុន្តែវាត្រូវបាននាំចូលទៅប្រទេសថៃ ដោយប្រទេសឥណ្ឌូនេស៊ី កាលពីឆ្នាំ ១៩៤៧ សម្រាប់ទប់ស្កាត់ការបាក់ច្រាំងទន្លេ និងសម្រាប់ប្រើជាជីធម្មជាតិនៅក្នុងចំការថ្នាំជក់។[6]

សព្វថ្ងៃនេះ ដើមក្លបយក្សត្រូវបាននាំចូល រាលដាល លុកលុយ និងបន្ទាប់មកក្លាយជាពពួករាតត្បាតនៅកម្ពុជា បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងក្នុងតំបន់ជាច្រើនលើពិភពលោក។ វាជាពពួករាតត្បាតនៅក្នុងតំបន់ដីសើម មាត់បឹង មាត់ទន្លេ និងទំនាបលិចទឹកនៅទូទាំងប្រទេសកម្ពុជា និងបន្តសាយភាយនៅទូទាំងពិភពលោក ពោលគឺគ្រប់កន្លែងដែលមានទឹកហូរនាំយកគ្រាប់វាទៅជាមួយ។[7] នៅឆ្នាំ១៩៤៩ ដើមក្លបយក្ស ត្រូវបានគេរកឃើញនៅភាគខាងជើងប្រទេសថៃ និងសាយភាយទៅប្រទេសវៀតណាមនៅមុនឆ្នាំ១៩៧០។[8] រុក្ខជាតិចង្រៃនេះ បានបន្តរាតត្បាតខេត្តឡុងអាន[9] និងបានរាតត្បាតនៅទូទាំងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៨០តមក[10] ជាពិសេស នៅតាមដងទន្លេមេគង្គ ដែលរហូតមកទល់ពេលនេះ វាបានគ្របដណ្តប់តំបន់ទំនាបលិចទឹក តំបន់ដីសើម និងដីចំការបោះបង់ចោល សរុបជាច្រើនពាន់ហិចតា។[11] រហូតដល់ឆ្នាំ ១៩៩៧ ដើមក្លបយក្ស បានរាតត្បាតខេត្តជាច្រើននៅកម្ពុជា ដែលរួមមាន ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្តាល កំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រៃវែង ស្វាយរៀង តាកែវ និងតំបន់មួយចំនួនក្នុងខេត្តកំពង់ស្ពឺ[12]។

# គោលបំណងនៃឯកសារនេះ

ឯកសារនេះ លើកឡើងជាអនុសាសន៍អំពីវិធីដ៏ប្រសើរបំផុត ដើម្បីផ្សព្វផ្សាយ និងកែប្រែឥរិយាបថ ក្នុងចំណោមសាធារណជនទូទៅ និងក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីឆ្ពោះទៅរកការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ដែលទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត។

គោលបំណងរួមនៃឯកសារនេះគឺ៖

---

[3] S.C. Renner, Nuon V., & Jonthan, C.E. (2011): Observations on the spread and extent of alien invasive plant species in six protected areas in Cambodia
[4] WCS (2000), An assessment of exotic species in Tonlesap Biospear Reserve
[5] Sam N., Hav V. & Ouk V. (2003) FiA Country Report on Present Status of Alien species in Aquaculture and Aquatic ecosystem in Cambodia
[6] Napompeth, 1983; Wara-Aswapati, 1983
[7] IUCN
[8] Thi et al., 2004
[9] Triet et al., 2004
[10] Vanna and Nang, 2003
[11] Samouth, 2004
[12] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងដើមក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្នួលស្ទឹងសែន ក្រសួងបរិស្ថាន នៃប្រទេសកម្ពុជា ឆ្នាំ២០១៣

- កំណត់សារគន្លឹះដែលទាមទារឱ្យមានការផ្សព្វផ្សាយទូលំទូលាយ ដើម្បីបង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធ/សាធារណជន នៅក្នុងការដោះស្រាយបញ្ហាប្រភេទទន្រ្ទានរាតត្បាត
- កំណត់ក្រុមគោលដៅសំខាន់ៗ ដែលអាចបង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ធនធាន
- បញ្ជ្រាបទិដ្ឋភាពសំខាន់ៗជុំវិញបញ្ហាប្រភេទទន្រ្ទានរាតត្បាត ដល់អ្នកតាក់តែងគោលនយោបាយ
- លើកអនុសាសន៍អំពីដំណោះស្រាយដែលមានប្រសិទ្ធិភាព ដល់ក្រុមគោលដៅសំខាន់ៗ ដែលរួមទាំងសាធារណជនទូទៅផងដែរ។

# អនុក្រមជាយុទ្ធសាស្ត្រ

ឯកសារនេះចែកចេញជាបួនយុទ្ធសាស្ត្រគឺ៖

- **យុទ្ធសាស្ត្រទី១៖** បង្កើតមធ្យោបាយផ្សព្វផ្សាយមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយរួមបញ្ចូលសារសំខាន់ៗ និងភាសាងាយយល់
- **យុទ្ធសាស្ត្រទី២៖** ផ្សព្វផ្សាយ និងលើកកំពស់ ការចូលរួមពីអ្នកពាក់ព័ន្ធនានា
- **យុទ្ធសាស្ត្រទី៣៖** ផ្សព្វផ្សាយជាមួយសាធារណជនទូទៅ និងលើកកំពស់ការយល់ដឹងជាសាធារណៈ
- **យុទ្ធសាស្ត្រទី៤៖** បណ្តុះបណ្តាល និងការអប់រំ។

តាមរយៈការគ្រប់គ្រងវិធីផ្សព្វផ្សាយជាលំដាប់លំដោយ និងខណៈពេលដែលដឹងថា មានអ្នកពាក់ព័ន្ធខ្លះបានចូលរួមរួចមកហើយក៏ដោយ ក៏យើងនៅតែមានគោលបំណងបង្កើនការយល់ដឹង និងការចូលរួមពីសំណាក់សាធារណជន និងអ្នកពាក់ព័ន្ធនានា ទៅតាមវិធីសាស្ត្រ និងរចនាសម្ព័ន្ធជាក់លាក់មួយ ។

ក. បង្កើនការយល់ដឹង និងការទទួលស្គាល់អំពីប្រភេទទន្រ្ទានរាតត្បាត ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដែលពុំទាន់បានចូលរួមពេញលេញនៅឡើយ

ខ. បង្កើនការយល់ដឹង និងការទទួលស្គាល់អំពីប្រភេទទន្រ្ទានរាតត្បាត ក្នុងចំណោមសាធារណជនទូទៅ តាមរយៈការផ្សព្វផ្សាយដោយផ្ទាល់ និងធ្វើការក្រោមភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមពេញលេញរួចហើយ

គ. ធ្វើការក្រោមភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ និងផ្សព្វផ្សាយដោយផ្ទាល់ដល់សាធារណជន។ បង្កើនការយល់ដឹង តាមរយៈការផ្តល់ការណែនាំ និងព័ត៌មានសុក្រិត្យ ដើម្បីឱ្យមានការចូលរួមទាំងអស់គ្នា

ឃ. ធ្វើឱ្យមានការកែប្រែឥរិយាបថ និងអាកប្បកិរិយា ពោលគឺប្រជាជនចាប់ផ្តើមចាត់វិធានការសំខាន់ៗ

ង. បង្កើតបរិយាកាសនយោបាយ ដើម្បីឱ្យមានការកែប្រែច្បាប់ និងបង្កើតការត្រួតពិនិត្យចាំបាច់នានា។

### *ការវិភាគស្ថានភាព*

ទីប្រឹក្សាជាតិបានធ្វើការវិភាគដំបូងអំពីភាពខ្លាំង និងភាពខ្សោយនៃការផ្សព្វផ្សាយ។ ការវិភាគនេះត្រូវបានពង្រីកទៅជាលក្ខខណ្ឌអំណោយផល និងឧបសគ្គ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងមានចែងដូចខាងក្រោម៖

# ការផ្សព្វផ្សាយទូលំទូលាយ

*សារគន្លឹះ និងការប្រើភាសា*

សារគន្លឹះដែលយើងត្រូវការបញ្ជូន ឬផ្ទេរ គឺថាយើងចែករំលែកការទទួលខុសត្រូវលើបញ្ហានេះ និងធ្វើសកម្មភាពដើម្បីកាត់បន្ថយបញ្ហាដែលកើតឡើង។ នេះជាបញ្ហាមួយដែលបុគ្គលនានាអាចធ្វើឱ្យមានភាពខុសគ្នាតាមរយៈសកម្មភាពរបស់ពួកគេ ដូច្នេះវាជាចំណុចវិជ្ជមានមួយសម្រាប់ផ្សព្វផ្សាយ។ ការសង្កត់ធ្ងន់លើការទទួលខុសត្រូវរួម គឺជាគន្លឹះមួយ ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋឱ្យធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ ក៏ដូចជា បញ្ចៀសការស្តីបន្ទោសដល់អ្នកទាំងឡាយនៅក្នុងវិស័យនានា ដែលពាក់ព័ន្ធជាមួយលំហូរនៃការរាលដាលសំខាន់ៗ របស់ប្រភេទទន្រ្ទានរាតត្បាតទាំងនោះ។

និយមន័យសម្រាប់ពាក្យប្រភេទទន្រ្ទានរាតត្បាតដែលរដ្ឋាភិបាលប្រើប្រាស់ ត្រូវបានស្រង់ចេញពីអនុសញ្ញាស្តីពីជីវៈចម្រុះ។ ទោះជាយ៉ាងណាក៏ដោយ មានការទទួលស្គាល់អំពីតម្រូវការឱ្យមាននិយមន័យផ្សេងមួយនៅពេលផ្សព្វផ្សាយជាមួយសាធារណជន និងក្រុមអ្នកពាក់ព័ន្ធខ្លះ ដើម្បីងាយស្រួលយល់អំពីបញ្ហានេះ។

*<u>សារគន្លឹះ:</u>*

| ល.រ | សារ | សាររង |
|---|---|---|
| ១ | ទប់ស្កាត់ប្រភេទទន្រ្ទានរាតត្បាត ដើម្បីការពារជីវៈចម្រុះរបស់យើង | • ប្រភេទទន្រ្ទានរាតត្បាត អាចបង្កជាជំងឺរាតត្បាត<br>• ប្រភេទទន្រ្ទានរាតត្បាត អាចគំរាមកំហែងដល់ប្រភេទសត្វ និងរុក្ខជាតិក្នុងស្រុក<br>• ប្រភេទទន្រ្ទានរាតត្បាត អាចធ្វើឱ្យខាតបង់ជាពេលវេលា និងមាសប្រាក់របស់អ្នក |
| ២ | ប្រភេទទន្រ្ទានរាតត្បាតបង្កការគំរាមកំហែងមកលើរបបចិញ្ចឹមជីវិត វប្បធម៌ ប្រពៃណី និងរបៀបរស់នៅរបស់យើង | |
| ៣ | ត្រូវមានមោទនភាពចំពោះបេតិកភណ្ឌជាតិ បញ្ឈប់ការនាំចូលប្រភេទទន្រ្ទានរាតត្បាត និងការពារជាតិយើង | |
| ៤ | កំចាត់ប្រភេទទន្រ្ទានរាតត្បាត និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ | |
| ៥ | រស់នៅជាមួយធម្មជាតិប្រកបដោយភាពសុខដុមរមនា និងគ្មានប្រភេទទន្រ្ទានរាតត្បាត | |

# ការផ្សព្វផ្សាយជាមួយអ្នកពាក់ព័ន្ធ

ឯកសារនេះ ផ្តល់អភិក្រមជាយុទ្ធសាស្ត្រ ក្នុងការលើកកំពស់ការចូលរួមពីអ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនចំណេះដឹង និងការយល់ដឹង លើផែនការរបស់ក្រសួងបរិស្ថាន និងការធ្វើការជាមួយគ្នា ដើម្បីគាំទ្រដល់ការអនុវត្ត។

*ការកំណត់អាទិភាព និងវាយតម្លៃអ្នកពាក់ព័ន្ធ*

ក្នុងផ្នែកនេះ តម្រូវឱ្យមានការកំណត់អាទិភាព របស់អ្នកពាក់ព័ន្ធទាំងឡាយ ។ ការកំណត់អាទិភាពនេះ សម្រេចបាន តាមរយៈការវាយតម្លៃលើអ្នកពាក់ព័ន្ធនានា ដែលអនុវត្តដោយទីប្រឹក្សាគម្រោង។ អង្គការពាក់ព័ន្ធនីមួយៗ ត្រូវបានកំណត់ និងបញ្ចូលគ្នាជាក្រុមដែលអាចគ្រប់គ្រងបាន។ ក្រុមទាំងនេះត្រូវបានចាត់អាទិភាព ដោយផ្អែកលើឥទ្ធិពល ដែលទាក់ទងទៅនឹងការសម្រេចបានតាមគោលបំណង និងផែនការរបស់ក្រសួងបរិស្ថាន។ សម្រាប់ក្រុមនីមួយៗ យើងបានកំណត់បញ្ហាគន្លឹះ លទ្ធផលសម្រេចបាន សារគន្លឹះ និងសកម្មភាព។

អ្នកពាក់ព័ន្ធ ត្រូវបានចាត់ជា ៤ ក្រុមផ្សេងៗគ្នា៖

- អាជ្ញាធរដែនដី
- អង្គការអភិរក្ស
- គ្រឹះស្ថានឧត្តមសិក្សា
- មន្ត្រីរដ្ឋាភិបាល

*សកម្មភាពលើកកំពស់ការចូលរួមពីអ្នកពាក់ព័ន្ធ*

ការវាយតម្លៃអ្នកពាក់ព័ន្ធនេះ ផ្តល់ព័ត៌មានលំអិតជុំវិញការចូលរួមពីអ្នកពាក់ព័ន្ធ ឬទំនាក់ទំនងជាមូលដ្ឋាន។ អ្នកពាក់ព័ន្ធជាច្រើន ត្រូវបានលើកកំពស់សកម្មភាពចូលរួម ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយអំពីប្រភេទទន្រ្ទានពាតត្បាត ជាពិសេសការបង្កើនចំណេះដឹងសាធារណៈ។ នេះជាសកម្មភាពដំបូងៗ ដែលអាចបង្កើតការវាយតម្លៃអ្នកពាក់ព័ន្ធ ដោយផ្អែកលើសម្ភារៈនៃប្រព័ន្ធផ្សព្វផ្សាយដែលមានស្រាប់ រួមជាមួយឱកាសសក្តានុពល និងឧបសគ្គទាំងឡាយ[13]។

# ការផ្សព្វផ្សាយជាមួយសាធារណជន

ដោយសារតែផលប៉ះពាល់របស់ប្រភេទទន្រ្ទានពាតត្បាតមានកំរិតធំធេង ចាំបាច់តម្រូវឱ្យមានការកំណត់អាទិភាពនៃអ្នកចូលរួមដែលពាក់ព័ន្ធ។ ការកំណត់អាទិភាពនេះ នឹងជួយតម្រង់ទិសការផ្តល់ព័ត៌មានជាក់លាក់ឱ្យទៅដល់អ្នកចូលរួមពិតប្រាកដ ដើម្បីឱ្យបុគ្គលនីមួយៗ មានវិធានការចាំបាច់ចំពោះប្រភេទទន្រ្ទានពាតត្បាតទាំងនោះ។

អ្នកចូលរួមសំខាន់ៗ ដែលបានកំណត់យកតាមរយៈការវាយតម្លៃព័ត៌មាន លើកម្រិតនៃការយល់ដឹងអំពីប្រភេទទន្រ្ទានពាតត្បាត នៅតំបន់ស្នូលស្ទឹងសែន តំបន់ស្នូលព្រែកទាល់ និងចុងឃ្នាស។ អ្នកចូលរួមសំខាន់ៗទាំងនោះរួមមាន៖

- ប្រធានសហគមន៍
- កសិករ
- អ្នកនេសាទ
- សិស្ស និស្សិត (បឋមសិក្សា អនុវិទ្យាល័យ និងមហាវិទ្យាល័យ)
- ប្រជាសហគមន៍

---

13 សូមមើលឧបសម្ព័ន្ធ ១

# ការបណ្តុះបណ្តាល និងការអប់រំ

ផ្នែកនេះ ជាការឆ្លើយតបទៅនឹងបញ្ហាសំខាន់ៗនៃការបណ្តុះបណ្តាល ក៏ដូចជាការអប់រំនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងមហាវិទ្យាល័យ។

តាមរយៈការវាយតម្លៃនេះ ការបណ្តុះបណ្តាល ជាបញ្ហាចំបងមួយដែលចាំបាច់ត្រូវដោះស្រាយ នៅក្នុងយុទ្ធសាស្រ្តផ្សព្វផ្សាយនេះ។ លទ្ធផលរកឃើញបានបង្ហាញថា ការបង្កើនកម្រិតយល់ដឹង និងចំណេះដឹងប្រកបដោយវិជ្ជាជីវៈ និងចំណាប់អារម្មណ៍ គឺជាបញ្ហាគន្លឹះ ដើម្បីសម្រេចបានតាមគោលដៅ។ បច្ចុប្បន្ននេះ វគ្គបណ្តុះបណ្តាលក្នុងការកំណត់ប្រភេទ នៅមានកម្រិតនៅឡើយ ហើយក៏មិនមានការសម្របសម្រួលនៅតាមវិស័យ ក្នុងការទប់ស្កាត់ផលប៉ះពាល់របស់ប្រភេទទន្រ្ទានរាតត្បាតដែរ។ វគ្គបណ្តុះបណ្តាលនៅតាមវិស័យ មានឥទ្ធិពលធំធេង និងបន្ទាន់ជាងការអប់រំ ដែលវាមានឥទ្ធិពលតិច និងប្រើពេលវេលាយូរ។

តម្រូវឱ្យមានវគ្គបណ្តុះបណ្តាល សម្រាប់៖

- អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើការសម្រេចចិត្ត
- រដ្ឋាភិបាល និងភ្នាក់ងាររបស់ខ្លួន
- អង្គការអភិរក្ស
- អាជ្ញាធរដែនដី
- គ្រឹះស្ថានឧត្តមសិក្សា
- ពាណិជ្ជកម្ម/ ឧស្សាហកម្ម

*ក្រុមការងារ*

I. វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជំនាញ

វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជំនាញ អាចនាំមកនូវក្រុមអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍មួយ ដើម្បីកំណត់តម្រូវការរបស់អ្នកអប់រំ និងអ្នកបណ្តុះបណ្តាល ក៏ដូចជាតម្រូវការរបស់សិក្ខាកាម។ សិក្ខាសាលា អាចជួយយើង ក្នុងការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលមួយ ដែលមានការឯកភាពគ្នា (ប្រសិនបើចាំបាច់) លើប្រភេទទន្រ្ទានរាតត្បាត។

II. ការអប់រំជាកញ្ចប់

ចងក្រងព័ត៌មាន និងកញ្ចប់សកម្មភាព សម្រាប់គ្រូបណ្តុះបណ្តាល និងសិស្សានុសិស្ស ដើម្បីលើកកំពស់ការយល់ដឹង ថាតើអ្វីជាប្រភេទទន្រ្ទានរាតត្បាត ហើយអ្វីខ្លះជាផលប៉ះពាល់របស់ប្រភេទទន្រ្ទានរាតត្បាតទាំងនោះ ដល់សង្គម និងបរិស្ថានរបស់យើង។

III. ការទិញសម្ភារៈសិក្សា

ចូរក្រឡេកមើលជំរើសនៃការទិញសម្ភារៈសិក្សាឱ្យសិស្ស ដើម្បីជួយពួកគេក្នុងការកំណត់ប្រភេទទន្រ្ទានរាតត្បាត និងដើម្បីបង្កើនចំណាប់អារម្មណ៍ និងកិច្ចពិភាក្សានៅខាងក្រៅបន្ទប់រៀន។

# ផលប្រយោជន៍ និងឧបសគ្គ

*__វិធីនៃការផ្សព្វផ្សាយ__*

ផ្នែកនេះចែងអំពីវិធីនានាសម្រាប់ផ្សព្វផ្សាយសារ និងបង្ហាញពីផលប្រយោជន៍ និងឧបសគ្គរបស់វិធីនីមួយៗ។ នៅពេលជ្រើសរើសវិធីសម្រាប់ផ្សព្វផ្សាយសារ ត្រូវពិចារណាកត្តាមួយចំនួន (គោលការណ៍ដូចបានរៀបរាប់ខាងលើ ថ្លៃចំណាយ ពេលវេលា ក្រុមគោលដៅ និងព័ត៌មានដែលត្រូវផ្សព្វផ្សាយ)។ ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ វិធីផ្សព្វផ្សាយតាមបែបសហគមន៍ និងទំនាក់ទំនងរវាងបុគ្គល គួរតែយកមកប្រើប្រាស់ជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងគ្នាទៅវិញទៅមក និងបង្កើនឥទ្ធិពលជាអតិបរមា។ ការវាយតម្លៃបានបង្ហាញថា ជារឿយៗប្រសិទ្ធិភាពនៃសារដែលងាយយល់ បានដើរតួនាទីបង្កើនចំនួន និងប្រភេទនៃវិធី ដែលប្រើប្រាស់សម្រាប់ផ្សព្វផ្សាយសារទាំងនោះ[14]។

### I. ការបញ្ជូនតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ (វិទ្យុ ទូរទស្សន៍ សារព័ត៌មាន អ៊ីនធឺណិត និងសិល្បៈកម្លែងអប់រំ)

ការបញ្ជូនតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈមានប្រសិទ្ធិភាពខ្ពស់ និងអាចបញ្ជូនដល់ក្រុមគោលដៅ។ វិធីនៃការបញ្ជូនអាចមានចាប់ពី វិធីនៃការអប់រំ រហូតដល់ការកំសាន្ត និងការឃោសនា តាមរយៈ វិទ្យុ ទូរទស្សន៍ និងព័ត៌មានបោះពុម្ព ដូចជាទស្សនាវដ្តី សារព័ត៌មាន បញ្ចូរព័ត៌មានតាមទីសាធារណៈ និងតាមកន្លែងមានមនុស្សឆ្លងកាត់ និងអ៊ីនធឺណិត ជាអាទិ៍ វេបសាយ និងបណ្តាញព័ត៌មានសង្គម។ មធ្យោបាយទាំងនេះអាចមានប្រសិទ្ធិភាពខ្ពស់ នៅពេលប្រើប្រាស់ក្នុងបរិបទមូលដ្ឋាន និងមានឥទ្ធិពលជាខ្លាំងមកលើក្រុមមនុស្សផ្សេងៗគ្នា ។

| ក) ទូរទស្សន៍ | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ទ្រង់ទ្រាយធំ និងផ្សាយដល់មនុស្សច្រើន<br>• អាចផ្តោតលើក្រុមមនុស្សមិនចេះអក្សរ<br>• ធ្វើឱ្យចាប់អារម្មណ៍និងមានឥទ្ធិពលខ្លាំង<br>• ភាពយន្តភាគ អាចផ្តល់ជាការកំសាន្ត ការអប់រំ និងភាពទាក់ទាញការយកចិត្តទុកដាក់<br>• ប្រសិនបើរៀបចំបានល្អ ការអប់រំតាមរយៈកម្មវិធីកំសាន្ត អាចផ្តល់ផលចំណូលជាលក្ខណៈពាណិជ្ជកម្ម និងបង្កើតឱ្យមានការកែប្រែឥរិយាបថជាវិជ្ជមាន | • ពិបាកបង្កើតក្រុមគោល ឬក្រុមប្រៀបធៀប ដើម្បីវាស់ការកែប្រែឥរិយាបថ/ អាកប្បកិរិយា ឬបង្កើតលក្ខខណ្ឌពាក់ព័ន្ធ<br>• ក្រុមគោលដៅខ្លះមានលទ្ធភាពតិចតួចក្នុងការមើលទូរទស្សន៍<br>– នៅកម្ពុជា ភាគរយនៃគ្រួសារតាមជនបទដែលមានទូរទស្សន៍យ៉ាងហោចណាស់១គ្រឿង គឺមានត្រឹមតែ៥៣,៣% ប៉ុណ្ណោះ (ជម្រឿនប្រជាសាស្ត្រឆ្នាំ ២០០៨)<br>• ថ្លៃចំណាយខ្ពស់សម្រាប់ការផលិត<br>• ករណីរៀបចំមិនបានគ្រប់ជ្រុងជ្រោយនាំឱ្យមានផលប៉ះពាល់អវិជ្ជមានទ្រង់ទ្រាយធំ |

14 http://www.jhuccp.org/sites/all/files/A%20Field%20Guide%20to%20Designing%20Health%20Comm%20Strategy.pdf

*លទ្ធភាពនៃការប្រើប្រាស់សារតាមទូរទស្សន៍*

- វីដេអូខ្លី និងការបញ្ចាំងឡើងវិញនូវទិដ្ឋភាពនានាដែលផ្តោតលើប្រភេទទន្រ្ទានរាតត្បាត។ គួរពិចារណាបញ្ចូល"វីដេអូខ្លី" ទៅក្នុងកម្មវិធីទូរទស្សន៍ ដើម្បីឱ្យប្រជាជនចងចាំសាច់រឿង និងព័ត៌មានអំពីប្រភេទទន្រ្ទានរាតត្បាតនោះ។
  - ចាក់ផ្សាយតាមទូរទស្សន៍អំពីការពិភាក្សារបស់ក្រុមអ្នកជំនាញ។ គួរកត់សំគាល់ថាការពិភាក្សាបែបនេះត្រូវការឱ្យមានការគ្រោងទុកជាមុន ដើម្បីឱ្យប្រាកដថា សមាជិកក្នុងការពិភាក្សានេះយល់ច្បាស់អំពីគ្រប់បញ្ហាដែលត្រូវពិភាក្សា។ ការសាកល្បង និងសំណួរ-ចម្លើយដែលត្រៀមទុកជាមុន គួរតែបានរៀបចំសម្រាប់កិច្ចពិភាក្សារបស់ក្រុមមន្ត្រីមកពីក្រសួងបរិស្ថាន ដែលគ្រោងចូលរួមក្នុងការពិភាក្សាបែបនេះ ដើម្បីធានាឱ្យមានភាពច្បាស់លាស់ និងសង្គតិភាពនៃសារនានា។
  - ក្រុមអ្នកពាក់ព័ន្ធនានា (រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ គ្រឹះស្ថានសិក្សា និងអ្នកស្រាវជ្រាវ) គួរតែបានចូលរួម ដើម្បីបង្ហាញថាប្រភេទទន្រ្ទានរាតត្បាត គឺជាបញ្ហាអន្តរវិស័យ។
  - គួរពិចារណាអំពីយេនឌ័រ អាយុ និងភាពផ្សេងគ្នានៃពូជសាសន៍ ក្នុងចំណោមសមាជិកនៃក្រុមអ្នកពិភាក្សានេះផងដែរ។
- ក្រុមគោលដៅគួរតែអាចបង្ហាញពីភាពពាក់ព័ន្ធជាមួយវីដេអូខ្លី ខ្សែរឿង និងតួអង្គនីមួយៗ ដោយសារវាអាចជាមធ្យោបាយប្រកបដោយប្រសិទ្ធិភាពសម្រាប់ផ្សព្វផ្សាយព័ត៌មាន និងមានឥទ្ធិពលធ្វើឱ្យកែប្រែឥរិយាបថ។

| ខ) **វិទ្យុ** | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ទូលំទូលាយក្នុងចំណោមប្រជាជនជាគោលដៅ៖<br>– មនុស្សក្នុងតំបន់គោលដៅទាំងបី ដែលភាគច្រើនប្រកបរបរជាអ្នកនេសាទ និងដាំដំណាំ មានលទ្ធភាពមើលទូរទស្សន៍ផ្សាយចេញពីទីរួមខេត្តមានកម្រិតកំណត់ ប៉ុន្តែវិទ្យុផ្សាយចេញពីទីរួមស្រុក អាចគ្របដណ្តប់ ៧៥% នៃចំនួនគ្រួសារ<br>• អាចផ្សព្វផ្សាយដល់ក្រុមពលរដ្ឋមិនចេះអក្សរ<br>• ភាពយន្តភាគ អាចផ្តល់ជាការកំសាន្ត ការអប់រំ និងភាពទាក់ទាញការយកចិត្តទុកដាក់<br>• ថ្លៃចំណាយទាប<br>• ល្ខោនវិទ្យុ/ការជជែកតុមូលតាមវិទ្យុ អាចផលិតបានក្នុងពេលជាមួយគ្នា នឹងព័ត៌មានតាមវិទ្យុផងដែរ ដើម្បីកាត់បន្ថយពេលវេលា និងថ្លៃចំណាយ | • រឿងភាគតាមវិទ្យុ ទាមទាឱ្យមានការរៀបចំយ៉ាងល្អ និងមានប្រសិទ្ធិភាព ដោយសារតែអត្ថបទសំណេរ និងការផលិត អាចជាការលំបាក ត្រូវការពេលច្រើន និងចំណាយច្រើន<br>• កំណត់តម្រូវការចាំបាច់ ដើម្បីទទួលបាននិរន្តរភាព។ ដូច្នេះការបញ្ជូនសារទាន់ពេលវេលាអាចមិនសម្រេចបាន ដោយសារតែអាយុកាលយ៉ាងវែងនៃប្រព័ន្ធផ្សព្វផ្សាយសាធារណៈ |

*ការប្រើប្រាស់វិទ្យុ*

- ស្តាប់វិទ្យុ ឬ កម្មវិធីខ្លីៗប្រចាំសប្តាហ៍តាមវិទ្យុដែលចាក់ផ្សាយព័ត៌មានអំពីប្រភេទទន្រ្ទានរាតត្បាត
- កម្មវិធីវិទ្យុដែលមានការទូរស័ព្ទចូល ឬ មានការចោទ/ឆ្លើយ
- ការពិភាក្សាតុមូល - ភ្ញៀវអាចរាប់បញ្ចូលអ្នកជំនាញការ អ្នកស្រាវជ្រាវ តំណាងពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ សមាជិកសហគមន៍ អ្នកជំនួញ និងអ្នកដទៃទៀត ដែលនឹងចែករំលែកជាមួយអ្នកស្តាប់នូវបទពិសោធន៍ របស់ខ្លួនអំពីប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា
- ព័ត៌មានអំពីកម្មវិធីតាមវិទ្យុអាចផ្សព្វផ្សាយតាមរយៈការចែកចាយផ្ទាំងរូបភាពនិងប័ណ្ណនៅតាមទីសាធារណៈ

| **គ) សារព័ត៌មាន** | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ចំណាយតិចសម្រាប់បង្កើតរចនាបថ<br>• ខ្លឹមសារតាមមូលដ្ឋាន<br>• អាចទិញទំព័រសម្រាប់ចុះផ្សាយ | • ការចែកចាយមិនបានគ្រប់គ្រាន់។ អនក្ខរកម្ម និងទំលាប់របស់ប្រជាជនជាច្រើនតាមជនបទ ដែលមិនសូវនិយមអាន អាចកាត់បន្ថយប្រសិទ្ធិភាពនៃវិធីនេះ |

*លទ្ធភាពនៃការប្រើប្រាស់សារព័ត៌មាន*

- ចុះផ្សាយខ្សែរឿង/ករណីសិក្សា/យោបល់ ឬទស្សនៈរបស់អ្នកនិពន្ធ ដែលទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វានៅក្នុងសារព័ត៌មានជាតិ/ក្នុងមូលដ្ឋាន។ ខ្សែរឿងរាប់បញ្ចូលទាំងរឿងស្តីពីជោគជ័យ និងអំពីការប្រឈមនានាផងដែរ។

| **ឃ) ផ្ទាំងប្រកាសផ្សាយព័ត៌មាន និងគំនូរតាមជញ្ជាំង** | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ឧបករណ៍បង្ហាញតាមរូបភាពដែលអាចផ្សព្វផ្សាយដល់ក្រុមគោលដៅទាំងជាអ្នកមិនចេះអក្សរនិងអ្នកចេះអក្សរ<br>• រូបតាមជញ្ជាំងអាចធ្វើបានដោយចំណាយតិច និងអាចប្រើប្រាស់ជាសកម្មភាពផ្សព្វផ្សាយ ដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីសហគមន៍<br>• អាចប្រើប្រាស់ជាសកម្មភាពទាក់ទាញការចូលរួមរបស់សហគមន៍ | • ថ្លៃចំណាយ និងបែបបទដើម្បីសុំកន្លែងតម្លើង<br>• មានពេលកំណត់ក្នុងការផ្សព្វផ្សាយដល់គោលដៅ។ ដោយផ្តោតលើមនុស្សដែលធ្វើដំណើរ ពួកគេចំណាយពេលត្រឹម ២ ឬ ៣វិនាទី ដើម្បីក្រលេកមើលផ្ទាំងព័ត៌មាន ឬគំនូសទាំងនេះ<br>• លំបាកវាស់ប្រសិទ្ធិភាព<br>• អាចផ្សព្វផ្សាយព័ត៌មានក្នុងកម្រិតកំណត់ |

*លទ្ធភាពនៃការប្រើប្រាស់ផ្ទាំងប្រកាសផ្សាយព័ត៌មាន*

- អាចដាក់តាមទីតាំងយុទ្ធសាស្ត្រ និងដែលលេចធ្លោ ដូចជា តាមផ្លូវជាតិ ការិយាល័យស្រុក និងសាលារៀន។ល។

| ង) វេបសាយ | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • អ៊ិនធឺណិត គឺជាប្រភពព័ត៌មាននាំមុខមួយ សម្រាប់មនុស្សជាច្រើនលើពិភពលោក និងត្រូវបានគេមើលឃើញថាជាប្រភពព័ត៌មានដែលអាចទុកចិត្តបាន | • ការសាយភាយអ៊ិនធឺណិតក្នុងចំណោមក្រុមគោលដៅ នៅមានកម្រិតទាប។<br>– នៅកម្ពុជា ប្រជាជនតិចជាង ២% ប្រើប្រាស់អ៊ិនធឺណិត (ការិយាល័យស្ថិតិនៃ អ.ស.ប ឆ្នាំ ២០១០)<br>• ថ្លៃចំណាយ និងពេលវេលា ដើម្បីតម្លើង និងថែរក្សាវេបសាយ |

ប្រភព៖ internetworldstats.com

*លទ្ធភាពក្នុងការប្រើប្រាស់*

- ក្រសួងនានារបស់រដ្ឋាភិបាលដែលធ្វើការក្នុងវិស័យបរិស្ថាន ជលផល និងកសិកម្ម គួរមានព័ត៌មានថ្មីៗនៅលើវេបសាយរបស់ខ្លួន សម្រាប់អ្នកសិក្សារៀនសូត្រ។ វេបសាយនេះគួរតែមានបញ្ជីឈ្មោះប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា។

| ច) បណ្តាញព័ត៌មានសង្គម (ដែលរួមទាំង ទូរស័ព្ទចល័ត ហ្វេសប៊ុក ទ្វីតធ័រ និងគេហទំព័រដែលប្រើប្រាស់ក្នុងបរិបទនៅមូលដ្ឋាន) | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • អត្រាប្រើប្រាស់ទូរស័ព្ទចល័តមានកម្រិតខ្ពស់<br>– នៅកម្ពុជា ប្រជាជន ៥៤% អាចប្រើប្រាស់បណ្តាញទូរស័ព្ទចល័ត[15]<br>• អាចផ្តោតលើយុវជន<br>• អាចធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងចំណាយតិច ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃច្បាប់ និងងាយកែសម្រួលអាសយដ្ឋានទាក់ទង<br>• អាចចំណាយតិច(មិនអស់ថ្លៃ)លើការបង្កើតទំព័រហ្វេសប៊ុក តែត្រូវការចំណាយពេលដើម្បីធ្វើបច្ចុប្បន្នភាព | • អត្រាសាយភាយហ្វេសប៊ុកមានកម្រិតទាប<br>• ព័ត៌មានអាចមើលឃើញរយៈពេលខ្លី មុននឹងត្រូវជំនួសដោយ សារ/ព័ត៌មានថ្មីៗ<br>• ការប្រើប្រាស់ទូរស័ព្ទទំនើបៗ ដែលអាចភ្ជាប់ប្រព័ន្ធអ៊ិនធឺណិត នៅមានកម្រិតកំណត់<br>• ការប្តេជ្ញាចំណាយពេលវេលា និងហិរញ្ញវត្ថុ (ប្រសិនបើចុះកិច្ចសន្យាជាមួយភ្នាក់ងារពីខាងក្រៅដើម្បីគ្រប់គ្រងទំព័រនោះ) ដើម្បីថែរក្សាទំព័រព័ត៌មានសង្គម និងទាក់ទាញសហគមន៍អ្នកប្រើប្រាស់អ៊ិនធឺណិត |

15 United Nationals Economic and Social Commission for Asia and the Pacific (2013) “Statistical Yearbook for Asia and the Pacific” accessed 11th January 2013 http://www.unescap.org/stat/data/syb2013/ESCAP-syb2013.pdf

*លទ្ធភាពប្រើប្រាស់បណ្តាញព័ត៌មានសង្គម*

- លើកទឹកចិត្តនិស្សិតតាមសាកលវិទ្យាល័យ មធ្យមសិក្សា អ្នកស្រាវជ្រាវ ។ល។ ឱ្យប្រើប្រាស់ព័ត៌មានដែលចែករំលែកតាមហ្វេសប៊ុកអំពីប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា
- បង្កើតទំព័រហ្វេសប៊ុកដែលចុះផ្សាយព័ត៌មានពិស្តារអំពីប្រភេទទន្រ្ទានរាតត្បាតនិងផលប៉ះពាល់របស់វា

## II.ការផ្សព្វផ្សាយផ្ទាល់នៅតាមសហគមន៍

ការផ្សព្វផ្សាយផ្ទាល់នៅតាមសហគមន៍ សំដៅលើការប្រាស្រ័យទាក់ទងទល់មុខគ្នា រវាងមនុស្សម្នាក់ជាមួយអ្នកសម្របសម្រួលការផ្សព្វផ្សាយ (មន្ទីរបរិស្ថានខេត្ត) រវាងមនុស្សម្នាក់ជាមួយមនុស្សមួយក្រុម និងរវាងមនុស្សមួយក្រុមជាមួយមនុស្សមួយក្រុមផ្សេងទៀត។ មធ្យោបាយនៃការផ្សព្វផ្សាយផ្ទាល់ អាចប្រើប្រាស់ភាសានិយាយ និងឧបករណ៍ផ្សព្វផ្សាយដោយរូបភាព។ វិធីទាំងនេះ ក៏អាចផ្តោតលើការផ្សព្វផ្សាយព័ត៌មានតាមរយៈក្រុមដែលមានស្រាប់ក្នុងសង្គម ដូចជា គ្រួសារ ឬ ក្រុមសហគមន៍ផងដែរ។

| **ក) ការផ្សព្វផ្សាយដោយផ្ទាល់** | |
|---|---|
| ***ផលប្រយោជន៍*** | ***ឧបសគ្គ*** |
| • ទោះបីមនុស្សជាច្រើនទទួលព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយសាធារណៈក៏ដោយ ក៏ការផ្សព្វផ្សាយផ្ទាល់និងព័ត៌មានដែលផ្តោតលើបុគ្គល ទំនងជាលើកទឹកចិត្តឱ្យមានឥរិយាបថថ្មី (UNICEF, 2005)<br>• អាចនាំឱ្យមានការកែប្រែឥរិយាបថតាមរយៈសហគមន៍ជាងការពឹងផ្អែកតែលើការបញ្ជូនសារពីស្ថាប័នថ្នាក់លើតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ | • អ្នកសម្របសម្រួលការផ្សព្វផ្សាយត្រូវមានជំនាញសមស្រប និងចំណេះដឹងអំពីការផ្សព្វផ្សាយ ការផ្លោះប្តូរព័ត៌មាន ការឆ្លើយសំណួរ និងមានអាកប្បកិរិយាសមស្របផងដែរ |

មានវិធីខុសៗគ្នាជាច្រើននៃការផ្សព្វផ្សាយព័ត៌មានដោយផ្ទាល់ ជាអាទិ៍៖

- ការបណ្តុះបណ្តាលនៅតាមការិយាល័យរបស់រដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល ដល់បុគ្គលិកឬមេដឹកនាំនៅតាមមូលដ្ឋាន
- ការផ្តល់វគ្គបណ្តុះបណ្តាលអំពីប្រភេទទន្រ្ទានរាតត្បាត នៅក្នុងសហគមន៍ ឬ តាមភូមិ
- ការថ្លែងសុន្ទរកថានៅតាមសាលារៀន ឬ ក្នុងកិច្ចប្រជុំនានាតាមមូលដ្ឋាន
- ការចែកផ្សាយព័ត៌មាននៅតាមកិច្ចប្រជុំក្នុងសហគមន៍ ឬ ក្នុងពិធីបុណ្យកំសាន្តនានា

## III. ឯកសារបោះពុម្ព និងសម្ភារៈសម្រាប់ចែកផ្សាយ

| ក) ផ្ទាំងព័ត៌មាន | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ប្រសិទ្ធិភាពខ្ពស់ខាងថ្លៃចំណាយ<br>• មធ្យោបាយមានប្រសិទ្ធិភាពខាងទីផ្សារ<br>• ងាយស្រួលប្រើប្រាស់ សម្រាប់អ្នកចេះអក្សរ តាមរយៈការប្រើភាសា និងរូបភាពងាយយល់។ល។<br>• រួមផ្សំជាឧបករណ៍ក្នុងវគ្គបណ្តុះបណ្តាល | • វិសាលភាពផ្សព្វផ្សាយក្នុងកម្រិតកំណត់<br>• ប្រើប្រាស់តាមទីកន្លែងក្នុងអគារ<br>• រចនាបថ និងការបោះពុម្ពជាថ្មីត្រូវការព័ត៌មានបច្ចុប្បន្នភាព |

*លទ្ធភាពនៃការប្រើប្រាស់ផ្ទាំងព័ត៌មាន*

- គេអាចដាក់ផ្ទាំងព័ត៌មាននៅតាមទីតាំងយុទ្ធសាស្ត្រនានា ដូចជា ក្នុងមន្ទីរបរិស្ថានខេត្ត ការិយាល័យស្រុក ការិយាល័យឃុំ និងតាមសាលារៀន។

| ខ) ខិតប័ណ្ណ | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • ចំណាយតិចសម្រាប់បង្កើតរចនាបថ និងបោះពុម្ព<br>• ងាយចែកចាយ និងដាក់នៅតាមមន្ទីរបរិស្ថានខេត្ត ការិយាល័យស្រុក-ឃុំ សាលារៀន។ល។<br>• ងាយស្រួលប្រើ ដោយមានទាំងភាសាងាយៗ រូបភាព ផ្ទាំងរូបភាពថ្លុក<br>• អាចផ្តល់ព័ត៌មានទូលំទូលាយ និងពិស្តារ<br>• អាចប្រើប្រាស់ជាព័ត៌មានយូរអង្វែង | • រចនាបថ និងការបោះពុម្ពថ្មីត្រូវការព័ត៌មានបច្ចុប្បន្នភាព (ដូចជា ការប្រែប្រួលគោលនយោបាយ)<br>• ងាយស្រួលប្រើ និងអាចបោះបង់ចោល |

*លទ្ធភាពប្រើប្រាស់ខិតប័ណ្ណ*

- ខិត្តប័ណ្ណអាចយកទៅចែកចាយតាមសាលារៀន និងនៅក្នុងសកម្មភាពកៀងគរសហគមន៍
- ដាក់សម្រាប់ចែកតាមទីកន្លែងយុទ្ធសាស្ត្រដូចជា មន្ទីរបរិស្ថានខេត្ត ការិយាល័យស្រុក ឃុំ និងសាលារៀន

## IV. សិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ ការប្រជុំបណ្តាញ និងវគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ

ការយល់ដឹងនៅថ្នាក់ធ្វើសេចក្តីសម្រេច នឹងនាំទៅរកការធ្វើសេចក្តីសម្រេចប្រកបដោយព័ត៌មានគ្រប់គ្រាន់ និងការគាំទ្រខាងនយោបាយបានប្រសើរជាងមុន និងអាចនាំឱ្យមានធនធានកាន់តែច្រើនជាងមុន។ ជា

រឿយៗ គម្រោងពុំបានផ្តល់មូលនិធិ ឬការគាំទ្រចាំបាច់ ដល់ថ្នាក់ដឹកនាំគម្រោងឡើយ ដោយសារអ្នកធ្វើសេចក្តីសម្រេច ពុំបានដឹងអំពីវិសាលភាពនៃបញ្ហានេះ។

ចូរឆ្លៀតឱកាសនេះដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើនបានចូលរួមនៅក្នុងសិក្ខាសាលា កិច្ចប្រជុំផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងអំពីបញ្ហាប្រភេទទន្រ្ទានពាតត្បាត និងបញ្ចុះបញ្ចូលអ្នកធ្វើសេចក្តីសម្រេចឱ្យអនុម័តលើគោលការណែនាំ ឬការអនុវត្តគំរូល្អណាមួយ។ ប្រើប្រាស់មធ្យោបាយនេះជាឱកាស សម្រាប់ពិភាក្សាអំពីវិធីដែលអាចធ្វើការជាមួយគ្នាដើម្បីអនុវត្តចំណាត់ការ។ បណ្តាញការងារនានា ផ្តល់ជាវិធីគន្លឹះមួយដើម្បីទាក់ទងជាមួយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

| ក) សិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ ការប្រជុំបណ្តាញ និងវគ្គបណ្តុះបណ្តាល | |
|---|---|
| *ផលប្រយោជន៍* | *ឧបសគ្គ* |
| • អាចបញ្ចុះបញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗ<br>• បង្កើនការគាំទ្រខាងនយោបាយ/ធនធាន<br>• ប្រើប្រាស់ជាឧបករណ៍ក្នុងវគ្គបណ្តុះបណ្តាល | • វិសាលភាពគ្របដណ្តប់មានកម្រិតកំណត់<br>• ចំណាយខ្ពស់ |

មានវិធីខុសៗគ្នាជាច្រើននៃការផ្សព្វផ្សាយផ្ទាល់ ដែលមានសកម្មភាពមួយចំនួនដូចតទៅ៖

- ការចាត់ចែងសិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ ការប្រជុំបណ្តាញ និងការអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីចូលរួមក្នុងកិច្ចពិភាក្សា និងលើកអនុសាសន៍
- ផ្តល់វគ្គបណ្តុះបណ្តាលអំពីប្រភេទទន្រ្ទានពាតត្បាតដល់មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន។

*<u>ចំណុចផ្សព្វផ្សាយ</u>*

ចំណុចផ្សព្វផ្សាយ គឺពេលវេលា និងទីកន្លែង ដែលត្រូវផ្សព្វផ្សាយសារនានា ដល់ក្រុមគោលដៅ។ ចំណុចផ្សព្វផ្សាយទាំងនោះមានជាអាទិ៍ ការផ្សព្វផ្សាយតាមរូបភាពខុសៗគ្នាជាលក្ខណៈផ្លូវការ និងមិនផ្លូវការ ដែលរាប់ចាប់ពីវគ្គបណ្តុះបណ្តាលដែលផ្តោតទៅលើប្រភេទទន្រ្ទានពាតត្បាត និងផលប៉ះពាល់របស់វា រហូតដល់វិធីងាយៗ ដែលអាចឱ្យបុគ្គលនីមួយៗ យកខិតប័ណ្ណដោយខ្លួនឯងបាន។ ដោយសារពេលវេលាផ្សព្វផ្សាយសារ និងធនធានដែលមាននៅចំណុចផ្សព្វផ្សាយខុសៗគ្នា ធ្វើឱ្យប្រសិទ្ធិភាពនៃការផ្សព្វផ្សាយនៅតាមចំណុចទាំងនេះ ក៏មានភាពខុសគ្នាផងដែរ។

ក្រុមគោលដៅខុសគ្នា (ដូចជា អ្នកនេសាទ កសិករ យុវជន និងអ្នកសិក្សា) អាចជាគោលដៅសម្រាប់ការផ្សព្វផ្សាយនៅតាមចំណុចផ្សព្វផ្សាយខុសៗគ្នា។ ការពិភាក្សាពិស្តារបន្ថែមទៀតអំពីក្រុមគោលដៅមាននៅក្នុងផ្នែកខាងក្រោម។

- **សហគមន៍ ឬ វត្ត៖** ទីតាំងទាំងនេះអាចប្រើប្រាស់សម្រាប់ចាត់ចែងការប្រជុំនានានៅតាមភូមិ ជាមួយក្រុមគោលដៅផ្សេងៗគ្នា ដូចជាកិច្ចពិភាក្សាជាក្រុមជាមួយក្រុមគោលដៅ ការបញ្ចាំងភាពយន្តឯកសារវីដេអូខ្លីៗ។ល។ អ្នកសម្របសម្រួលអាចប្រើប្រាស់កិច្ចពិភាក្សាទាំងនេះ ដើម្បីចែកផ្សាយកូនសៀវភៅ ខិតប័ណ្ណ និងផ្ទាំងព័ត៌មាន។

- **ការប្រជុំតាមភូមិ៖** អាជ្ញាធរភូមិ ត្រូវប្រមូលផ្តុំអ្នកចូលរួមមកពីភូមិគោលដៅ ដើម្បីចូលរួមក្នុងការប្រជុំ។
- **ការប្រជុំក្រុមអ្នកមានអាជីពដូចគ្នា៖** ការប្រជុំជាមួយក្រុមដែលមានអាជីពដូចគ្នា ដូចជាក្រុមអ្នកនេសាទ និងកសិករ អាចមានរៀបចំរួចមកហើយនៅថ្នាក់ខេត្ត ឃុំ ឬ ភូមិ ។
- **សាលារៀន៖** ទស្សនកិច្ចតាមសាលារៀន ក៏ត្រូវមានការពិភាក្សាពិស្តារផងដែរជាមួយនាយកសាលាមុននឹងធ្វើទស្សនកិច្ច និងចែកចាយសម្ភារៈផ្សព្វផ្សាយនៅចំពោះមុខវត្តមានលោកគ្រូ អ្នកគ្រូ ដោយហេតុថាសិស្សអាចមានសំណួរក្នុងរយៈពេលជាច្រើនសប្តាហ៍ក្រោយមក។ ត្រូវផ្តល់ព័ត៌មានអំពីប្រភេទទន្ទ្រានរាតត្បាត និងផលប៉ះពាល់របស់វា ដល់យុវជនផងដែរ ដើម្បីជួយពួកគេចូលរួមក្នុងការគ្រប់គ្រង។
- **សិក្ខាសាលា ឬការប្រជុំផ្សព្វផ្សាយ៖** រៀបចំសិក្ខាសាលា ឬការប្រជុំផ្សព្វផ្សាយ និងអញ្ជើញអ្នកពាក់ព័ន្ធសំខាន់ៗ ជាអាទិ៍ អ្នកតាក់តែងគោលនយោបាយ និងអ្នកស្រាវជ្រាវ ដើម្បីចូលរួមក្នុងពិធីនេះ។ ការចែករំលែកព័ត៌មានដែលទាក់ទងនឹងពពួកប្រភេទទន្ទ្រានរាតត្បាត និងផលប៉ះពាល់របស់វា ជារឿងដែលសំខាន់។

*<u>ក្រុមគោលដៅ</u>*

ប្រការសំខាន់គឺត្រូវគូសបញ្ជាក់ពីក្រុមគោលដៅសម្រាប់យុទ្ធសាស្ត្រផ្សព្វផ្សាយនេះ។ ក្រុមទាំងនេះអាចរាប់ចាប់ពី អ្នកតាក់តែងគោលនយោបាយ រហូតដល់សិស្សានុសិស្ស។ ប្រភេទនៃក្រុមគោលដៅនឹងបង្ហាញពីវិធីល្អបំផុតសម្រាប់អនុវត្ត ជំពូកនៃសារដែលត្រូវបញ្ជូន និងមធ្យោបាយដែលមានប្រសិទ្ធិភាពបំផុតសម្រាប់ការផ្សព្វផ្សាយ។

តារាងខាងក្រោមគ្រាន់តែជាការបង្ហាញត្រួសៗប៉ុណ្ណោះអំពីក្រុមគោលដៅខុសៗគ្នាដែលអាចស្ថិតនៅក្នុងចំណាត់ថ្នាក់ធំទូលាយនៃក្រុមគោលដៅជាអ្នកទទួលសារ។

*<u>សាធារណជនទូទៅ</u>*

សាធារណជនទូទៅអាចជាកត្តាជំរុញនៃបញ្ហាប្រភេទទន្ទ្រានរាតត្បាត ហើយក្រុមនេះគឺជាអ្នកដែលត្រូវប្រឈមនឹងផលប៉ះពាល់ដែលកើតឡើង។ ការគាំទ្រដល់សាធារណជនមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រជារួម អំពីប្រភេទទន្ទ្រានរាតត្បាត បានទទួលជោគជ័យ ក៏ដូចជា សម្រាប់កម្មវិធីជាក់លាក់ផងដែរ។ កង្វះចំណាប់អារម្មណ៍ពីសាធារណៈ ឬអរិយភាព អាចធ្វើឱ្យយុទ្ធសាស្ត្របែបនេះទទួលបរាជ័យ។

*<u>គ្រឹះស្ថានសិក្សា/សាលារៀន</u>*

គ្រឹះស្ថានសិក្សា និងសាលារៀន នៅគ្រប់លំដាប់ថ្នាក់ គឺជាចំណុចចាប់ផ្តើម ដើម្បីបង្កើត "ការយល់ដឹងអំពីប្រភេទទន្ទ្រានរាតត្បាត"។ ពួកគេអាចជាក្រុមដែលសកម្មបំផុតសម្រាប់ការបញ្ជូនសារនានា។

*<u>ក្រុមអ្នកពាក់ព័ន្ធជាក់លាក់</u>*

ក្រុមនេះមានជាអាទិ៍ អ្នកឯកទេស ដូចជាក្រុមអភិរក្សសត្វព្រៃ។ នៅពេលបញ្ហាប្រភេទទន្ទ្រានរាតត្បាតមានការពាក់ព័ន្ធនឹងចំណាប់អារម្មណ៍របស់ពួកគេ ពួកគេទំនងជាទទួលយកគំនិតអំពីការគ្រប់គ្រង និងការទប់ស្កាត់។ ពួកគេក៏ទំនងជាមានឆន្ទៈក្នុងការដើរតួយ៉ាងសំខាន់ផងដែរ នៅពេលដែលពួកគេយល់អំពីភាពខុសគ្នាដែលអាចកើតចេញពីការកែប្រែណាមួយ (ដូចជា ការកំចាត់ចោល*ដើមក្ដបយក្ស*)។

*ឧស្សាហកម្ម/ជំនួញ*

ក្រុមនេះមានជាអាទិ៍ ឧស្សាហកម្មដែលពាក់ព័ន្ធក្នុងការ រួមចំណែកបង្កើតបញ្ហា ឬបង្កផលប៉ះពាល់ដោយសារប្រភេទទន្រ្ទានរាតត្បាត (ដូចជា ក្រុមហ៊ុននាំចូល/នាំចេញទំនិញ ក្រុមហ៊ុនបញ្ជូនទំនិញ ប្រតិបត្តិករពាណិជ្ជករ)។

*អ្នកតាក់តែងគោលនយោបាយ*

អាស្រ័យលើស្ថានភាពជាក់ស្តែង ក្រុមនេះអាចរាប់បញ្ចូលតាំងពី រដ្ឋាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ មន្ត្រីនៅតាមលំដាប់ថ្នាក់ទាំងនោះ ទីភ្នាក់ងារ និងគ្រឹះស្ថាននានា។ ក្រុមនេះរាប់បញ្ចូលអ្នកដែលបង្កើតយុទ្ធសាស្ត្រនានា និងដែលមានឥទ្ធិពលលើគោលនយោបាយ ក៏ដូចជា អ្នកដែលពាក់ព័ន្ធក្នុងការអនុវត្តផងដែរ។

| ក្រុមគោលដៅ | សំណុំលក្ខណៈ | ឧបសគ្គក្នុងការកែប្រែឥរិយាបថ | សំណើយុទ្ធសាស្ត្រ |
|---|---|---|---|
| **សាធារណជនទូទៅ** | ចំណេះដឹង និងបទពិសោធន៍ អាចៈ<br>• មានឥទ្ធិពលលើសមាជិកដទៃក្នុងសហគមន៍របស់ខ្លួន<br>• កែប្រែឥរិយាបថរបស់អ្នកដទៃនិងបញ្ចុះបញ្ចូលអ្នកទាំងនោះឱ្យជួយគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត | • មិនឃើញថា ប្រភេទទន្រ្ទានរាតត្បាតជាបញ្ហា<br>• ពុំមានធនធានសម្រាប់គ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត<br>• ខ្វះព័ត៌មានអំពីវិធីគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត<br>• គិតថាបញ្ហានេះធំពេក | • ចែកចាយផ្ទាំងព័ត៌មាននិងកូនសៀវភៅព័ត៌មាននៅតាមភូមិ និងជុំវិញសាលារៀន<br>• ចាត់ចែងនិងសម្របសម្រួលការប្រជុំតាមទីកន្លែងសមស្របនៅថ្នាក់ភូមិ(វត្តឬទីសាធារណៈនៅក្នុងភូមិ)<br>• ពិចារណាពេលវេលាសម្រាប់ការប្រជុំដើម្បីជៀសវាងអ្នកចូលរួមជាប់រវល់ |
| **គ្រឹះស្ថានសិក្សា/សាលារៀន** | ជាក្រុមដែលមានប្រសិទ្ធិ ភាពបំផុតក្នុងការបញ្ជូនសារនានា | • មានព័ត៌មានតិចតួចដែលទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត<br>• គ្មានកម្មវិធីអន្តរាគមន៍សម្រាប់និស្សិត/ អ្នកសិក្សាស្រាវជ្រាវ | • បង្កើតកម្មវិធីស្រាវជ្រាវ<br>• ចែកផ្ទាំងព័ត៌មាននិងកូនសៀវភៅព័ត៌មាននៅក្នុងភូមិនិងជុំវិញសាលារៀន<br>• ចាត់ចែងនិងសម្របសម្រួលការប្រជុំតាមទីកន្លែងសមស្របក្នុងសាលារៀនឬសាកលវិទ្យាល័យ |
| **អ្នកពាក់ព័ន្ធនានា** | ចែករំលែកបទពិសោធន៍ | ការគាំទ្រហិរញ្ញវត្ថុក្នុងកម្រិតកំណត់ | • ការកសាងសមត្ថភាព និងសកម្មភាពបង្កើនការយល់ដឹង |

| | | | |
|---|---|---|---|
| | | | ដូចជា សិក្ខាសាលាអំពីប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា<br>• ការពិភាក្សាជាក្រុមដែលគូសបញ្ជាក់ពីលទ្ធផលដែលមានសក្តានុពលដើម្បីកំចាត់ ឬកាត់បន្ថយប្រភេទទន្រ្ទានរាតត្បាត<br>• អនុសាសន៍ទៅអ្នកកសាងគោលនយោបាយ |
| **អ្នកតាក់តែងគោលនយោបាយ** | បង្កើតយុទ្ធសាស្រ្ត និងបញ្ចុះបញ្ចូលអ្នកតាក់តែងគោលនយោបាយ ក៏ដូចជាអ្នកទាំងឡាយដែលពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយទាំងនោះផងដែរ | • មានព័ត៌មានតិចតួចទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត<br>• មានការគាំទ្រហិរញ្ញវត្ថុក្នុងកម្រិតកំណត់ | • កសាងសមត្ថភាព និងសកម្មភាពបង្កើនការយល់ដឹងដូចជា សិក្ខាសាលាស្តីពីប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា<br>• ការពិភាក្សាជាក្រុមដែលគូសបញ្ជាក់អំពីលទ្ធផលដែលមានសក្តានុពលដើម្បីកំចាត់ ឬកាត់បន្ថយប្រភេទទន្រ្ទានរាតត្បាត |

# ឧបសម្ព័ន្ធ I

## ការវាយតម្លៃកម្រិតយល់ដឹងអំពីប្រភេទទន្រ្ទានរាតត្បាត ជាពិសេស ដើមក្លបយក្ស នៅតំបន់ស្នូលស្ទឹងសែន ព្រែកទាល់ និងចុងឃ្នាស

### ១. សេចក្តីផ្តើម

តំបន់គោលដៅចំនួនបី [16] ដែលបានជ្រើសរើសសម្រាប់ធ្វើការវាយតម្លៃនេះ គឺជាតំបន់ព្រៃលិចទឹកប្លែកពីគេ រួមផ្សំជាមួយភូមិបណ្តែតទឹក ដែលមានគ្រួសារភាគច្រើនរស់នៅក្នុងផ្ទះបណ្តែតទឹក។ ការនេសាទ និងការដាំដំណាំ គឺជាមុខរបរចំបងរបស់ប្រជាជនទាំងនេះ។ អ្នកខ្លះរស់នៅជិតទន្លេ ដែលពួកគេដាំដំណាំតិចតួចផងដែរ។

នៅក្នុងតំបន់ស្នូលស្ទឹងសែន (ខេត្តកំពង់ធំ) ដែលតាំងនៅតាមដងស្ទឹងសែន ដែលជាកន្លែងជ្រើសរើសសម្រាប់ការវាយតម្លៃនេះ គឺជាតំបន់ព្រៃគ្មានការរំខានមួយទំហំសរុប ៦.៤០០ហិចតា។[17] កាលពីអតីតកាល ឃុំផាត់សណ្តាយដែលត្រូវបានជ្រើសរើសសម្រាប់គម្រោងអភិរក្ស និងអភិវឌ្ឍន៍ គឺជាកន្លែងសំបូរធនធានជលផល ដោយសារតែវត្តមានព្រៃលិចទឹក បឹង និងស្ទឹងនានា។[18]

យោងតាមការអង្កេតស្ថានភាពគោល[19] ដែលបានធ្វើឡើងនៅឆ្នាំ ២០១៣ អ្នកភូមិភាគច្រើនដែលរស់នៅជាអចិន្ត្រៃយ៍ក្នុងតំបន់នេះ(៨៣%) មានដីសម្រាប់ដាំដំណាំទំហំពី ០,៦ ដល់ ១,២ហិចតា។ អ្នកក្រៅពីនេះពុំមានដីដាំដំណាំឡើយ។

*<u>ប្រភេទទន្រ្ទានរាតត្បាត</u>*

ពពួករាតត្បាតចំនួន ១១ប្រភេទ ត្រូវបានរកឃើញនៅក្នុងតំបន់ស្នូលនេះ ក្នុងនោះមានបីប្រភេទជាត្រីមកពីក្រៅស្រុក ដែលមានឈ្មោះថា ត្រីកាបសាមញ្ញ ត្រីកាបស និងត្រីកាបឥណ្ឌា(រ៉ូហ៊ូ)។ ត្រីទាំងនេះត្រូវបាននេសាទជាធម្មតា ក្នុងបរិមាណតិចតួចនៅក្នុងបឹងទន្លេសាប និងនៅតាមដងទន្លេមេគង្គ។ ពពួករុក្ខជាតិរាតត្បាតទំនងជាមានរបាយក្នុងកម្រិតកំណត់ អាស្រ័យដោយលក្ខខណ្ឌបរិស្ថាន។ មានការរកឃើញថា ពពួករុក្ខជាតិក្រៅស្រុកខ្លះ ដូចជា candle bush, purging nut និងដើមក្លបយក្ស ភាគច្រើនមានដុះនៅតាមទីខ្ពស់ ចំណែកកំប្លោក និង seedbox មានតែនៅតាមទីទំនាប។[20]

រុក្ខជាតិក្រៅស្រុកមួយចំនួនមានការសាយភាយនៅក្នុងលក្ខខណ្ឌអេកូឡូស៊ីខុសៗគ្នាជុំវិញតំបន់ស្នូលស្ទឹងសែន។ ទាំងនៅទីខ្ពស់ និងទីទំនាប សុទ្ធតែមានពពួករុក្ខជាតិទាំងនេះក្នុងបរិមាណដូចគ្នា។ មានការរកឃើញថា ដើមក្លបយក្ស រាតត្បាតទំនាបលិចទឹកទាំងអស់ ដែលបានបន្សាយគ្រាប់ពូជ និងលូតលាស់ជារុក្ខជាតិ

---

[16] ព្រែកទាល់ ខេត្តបាត់ដំបង ចុងឃ្នាស ខេត្តសៀមរាប និងតំបន់ស្នូលស្ទឹងសែន ក្នុងខេត្តកំពង់ធំ

[17] MoE, 2007

[18] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្នូលស្ទឹងសែន ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ឆ្នាំ ២០១៣

[19] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្នូលស្ទឹងសែន ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ឆ្នាំ ២០១៣

[20] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងប្រក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្នូលស្ទឹងសែន ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ឆ្នាំ ២០១៣

ពេញវ័យ និងលូតលាស់ស្ថិតស្ថេរ។ ថ្មីៗនេះ មានសេចក្តីរាយការណ៍អំពីកំណើនពពួករុក្ខជាតិក្លបយក្ស និងបង្កជាការគំរាមកំហែងធំបំផុតចំពោះជីវៈចម្រុះ។

## ២. គោលបំណងនៃការវាយតម្លៃនេះ

ការវាយតម្លៃនេះមានគោលបំណងចំបងចំនួនពីរ៖

- វាយតម្លៃកម្រិតយល់ដឹងក្នុងចំណោមសាធារណជន អ្នកសិក្សា និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត ជាពិសេស ដើមក្លបយក្ស និងផលប៉ះពាល់របស់វា
- គាំទ្រដល់ការរៀបចំ យុទ្ធសាស្រ្តផ្សព្វផ្សាយជាតិសម្រាប់ការគ្រប់គ្រងប្រភេទទន្រ្ទានរាតត្បាត របស់គម្រោងFORIS នៅកម្ពុជា។

## ៣. វិធីសាស្រ្ត

របាយការណ៍វាយតម្លៃនេះបានផ្អែកលើទិន្នន័យដែលមានស្រាប់ផង និងទិន្នន័យបឋមផង។ ការសិក្សាវាយតម្លៃនេះមានគោលដៅពិនិត្យមើលចំណេះដឹងទូទៅរបស់សាធារណជន និងអ្នកពាក់ព័ន្ធនានាអំពីប្រភេទទន្រ្ទានរាតត្បាត ជាពិសេស ដើមក្លបយក្ស ដោយប្រើប្រាស់វិធីវាយតម្លៃបែបបរិមាណ និងគុណភាព។ ការប្រមូលទិន្នន័យបឋម បានធ្វើឡើងតាមរយៈការសម្ភាសន៍បុគ្គល និងការពិភាក្សាជាក្រុម។ ទិន្នន័យទាំងនេះត្រូវបានប្រើប្រាស់ជាមួយការវិភាគបែបគុណភាពលើលទ្ធផលពីការសម្ភាសន៍នានា និងការពិភាក្សាជាក្រុម ដែលគាំទ្រដោយបញ្ជីសំណួរដែលបានរៀបចំឡើងជាឧបករណ៍សម្រាប់ការប្រមូលទិន្នន័យបែបគុណភាព។ ក្នុងករណីធ្វើបាន មានការផ្តល់ព័ត៌មានតាមរយៈករណីសិក្សានានាដែលមានផ្តល់នៅក្នុងរបាយការណ៍នេះផងដែរ។

តាមរយៈការគាំទ្រពីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ដែលសម្របសម្រួលការជួបប្រជុំរបស់ទីប្រឹក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ក្នុងចំណោមមន្រ្តីរដ្ឋាភិបាល អ្នកសិក្សា អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងនៅតាមទីតាំងគម្រោង។ ជាបឋម ទីប្រឹក្សាបានទាក់ទងជាមួយមន្ទីរបរិស្ថានខេត្ត និងអាជ្ញាធរមូលដ្ឋាន ដើម្បីចាត់ចែងការពិភាក្សាជាក្រុម និងការសម្ភាសន៍ជាលក្ខណៈបុគ្គល។ ការកំណត់អ្នកទទួលការសម្ភាសន៍បានធ្វើឡើងតាមរយៈវិធីកំណត់សំណាកដែលមានគោលដៅជាក់លាក់៖ បុគ្គលជាគោលដៅនៅព្រែកទ័លក្នុងខេត្តបាត់ដំបង ចុងឃ្នាសក្នុងខេត្តសៀមរាប និងតំបន់ស្ទួលស្ទឹងសែនក្នុងខេត្តកំពង់ធំ ដែលក្រសួងបរិស្ថានបានជ្រើសជាទីតាំងគម្រោងសាកល្បង និងសាកលវិទ្យាល័យ សាលារៀនមធ្យមសិក្សា អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ។ អ្នកដែលបានទាក់ទងនៅក្នុងស្ថាប័នទាំងអស់នេះបានឯកភាពទទួលការសម្ភាសន៍ន៍។ លើសពីនេះ ក្រុមការងារគម្រោងបានធ្វើការសម្ភាសន៍ជាមួយអ្នកស្រាវជ្រាវ ដែលរួមទាំង អ្នកធ្វើបាឋកថានៅតាមសាកលវិទ្យាល័យ និងនិស្សិតផងដែរ។

ជារួម ការសម្ភាសន៍ន៍ និងការពិភាក្សាជាក្រុមបានធ្វើឡើងជាមួយ៖

- អ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលរួមទាំង អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងអ្នកស្រាវជ្រាវ (ការសម្ភាសន៍ន៍ជាលក្ខណៈបុគ្គល)
- និស្សិតសាកលវិទ្យាល័យ និងសិស្សសាលាមធ្យមសិក្សា (ការសម្ភាសន៍ន៍ជាក្រុម)
- ប្រធានសហគមន៍ (ការសម្ភាសន៍ន៍ជាលក្ខណៈបុគ្គល)
- ប្រធានមន្ទីរ និងមន្ត្រីល្បាតនៅថ្នាក់ខេត្ត (ការសម្ភាសន៍ន៍ជាលក្ខណៈបុគ្គល)

- ប្រជាសហគមន៍មូលដ្ឋាន (ការសម្ភាសន៍ជាក្រុម)។

*តារាង ១. ទំហំសំណាក*

| ក្រុមគោលដៅ | ទំហំសំណាក |
|---|---|
| អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងអ្នកស្រាវជ្រាវ | ៦ |
| និស្សិតសាកលវិទ្យាល័យ | ៤០ |
| សិស្សសាលាមធ្យមសិក្សា | ៤០ |
| ប្រធានសហគមន៍ | ២ |
| ប្រធានមន្ទីរ និងមន្ត្រីល្បាតនៅថ្នាក់ខេត្ត | ៦ |
| ប្រជាសហគមន៍មូលដ្ឋាន | ៥០ |

ក្រុមការងារគម្រោងបានធ្វើការវាយតម្លៃដោយគោរពតាមក្រមសីលធម៌ ដោយតែងប្រាប់អ្នកទទួលការសម្ភាសន៍អំពីមូលហេតុនៃការសិក្សានេះ និងសួរពួកគេថាតើពួកគេឯកភាពជាមួយដំណើរការសម្ភាសន៍ដែរឬទេ។ ក្រុមនេះក៏បានសុំការអនុញ្ញាតដើម្បីធ្វើការកត់ត្រាផងដែរ។ គ្មានការប្រើប្រាស់មីក្រូហ្វូនឡើយ។ ប្រសិនបើអ្នកទទួលការសម្ភាសន៍ពុំចង់ឱ្យមានការកត់ត្រាទេនោះ ចំណុចនេះត្រូវបានគោរពតាម (ទោះបីជួនកាល ការធ្វើបែបនេះបង្កជាការលំបាកក្នុងការកត់ត្រាទិន្នន័យសម្រាប់ការវិភាគនៅពេលក្រោយមកក៏ដោយ)។ គ្មានការប្រើប្រាស់ឈ្មោះឡើយ ប្រសិនបើអ្នកឆ្លើយសុំមិនបញ្ចេញឈ្មោះ។

ទិន្នន័យដែលមានស្រាប់ (ការសិក្សាស្រាវជ្រាវ និងរបាយការណ៍ដែលមានស្រាប់អំពីប្រភេទរាតត្បាតមកពីក្រៅស្រុក ទាំងក្នុងបរិបទនៃប្រទេសកម្ពុជា និងប្រទេសដទៃផងដែរ) ត្រូវបានពិនិត្យ ដើម្បីបង្កើតជាការពិនិត្យឯកសារសម្រាប់ផ្តល់ព័ត៌មានដែលមានស្រាប់សម្រាប់គាំទ្រដល់ការសិក្សានេះ។ ការពិនិត្យនេះមានគោលដៅផ្តល់ជាគំនិតអំពីទិដ្ឋភាពខុសៗគ្នា និងទីកន្លែងដែលមានដើមក្លបយក្ស។ របាយការណ៍ទាំងនេះត្រូវបានប្រើប្រាស់ផងដែរ ដើម្បីជួយនៅក្នុងការវិភាគទិន្នន័យបឋមនៅក្នុងការសិក្សានេះ។

## ៤. ឧបសគ្គនៅក្នុងការវាយតម្លៃនេះ

ឧបសគ្គដូចខាងក្រោម បានជួបប្រទះនៅក្នុងពេលធ្វើការវាយតម្លៃនេះ។ ផ្នែកនេះក៏បង្ហាញផងដែរអំពីវិធីដែលក្រុមអ្នកអនុវត្តគម្រោងបានប៉ុនប៉ងដោះស្រាយឧបសគ្គទាំងនោះ។

- ជួនកាលមានការលំបាកចូលក្នុងតំបន់គោលដៅ និងការចូលជួបក្រុមគោលដៅ ដោយសារតែលក្ខខណ្ឌនៃផ្លូវថ្នល់ និងការចាំបាច់ដើម្បីធ្វើដំណើរតាមទូក។ ក្រុមអ្នកអនុវត្តគម្រោងបានកែសម្រួលកាលវិភាគរបស់ខ្លួនដើម្បីឆ្លើយតបនឹងបញ្ហានេះ និងបានចាត់ចែងដើម្បីចូលដល់តំបន់គោលដៅតាមការគ្រោងទុក។
- ក្រុមអ្នកអនុវត្តគម្រោងបានរៀបចំកាលវិភាគនៅជុំវិញថ្ងៃបុណ្យជាតិរបស់កម្ពុជា ដែលធ្វើឡើងនៅក្នុងអំឡុងពេលនៃការវាយតម្លៃនេះ។

## ៥. របកគំហើញពីការវាយតម្លៃ និងការពិភាក្សា

ផ្នែកនេះបង្ហាញពីក្របខ័ណ្ឌវាយតម្លៃដូចដែលបានគ្រោងទុកពីដំបូង៖

***ដើមក្លបយក្ស និងផលប៉ះពាល់របស់វា***

ដើមក្លបយក្ស ត្រូវបានគេហៅនៅក្នុងតំបន់ស្ទួលស្ទឹងសែនថា "បន្លាក្លបយក្ស ឬ បន្លាអ៊ុយយ៉ាស់" ចំណែកនៅព្រែកទាល់ និងតំបន់ចុងឃ្នាស ត្រូវបានហៅថា "បន្លាក្លបយក្ស ឬ បន្លាយួន"។ អ្នកឆ្លើយទាំងអស់បានឱ្យដឹងថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិសាលភាពនៃរុក្ខជាតិក្លបយក្សបានរាលដាលយ៉ាងឆាប់រហ័ស ហើយស្ថានភាពនេះកាន់តែធ្ងន់ធ្ងរ។

នៅតំបន់ព្រែកទាល់ ប្រជាជនជឿថា ដើមក្លបយក្សត្រូវបានយោធានាំមកនៅក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិលក្នុងឆ្នាំ ១៩៨០ ដើម្បីបង្កើតជារបាំងការពារជុំវិញទាហាន។ តំបន់ចុងឃ្នាសទទួលស្គាល់ថា គ្រាប់ ដើមក្លបយក្សចូលមកតាមច្រាំងទន្លេ។ ចំណែកប្រជាជនដែលរស់នៅស្ទឹងសែន ឆ្លើយថាពួកគេមិនដឹង ឬមិនច្បាស់ទេថាវាមានប្រភពមកពីណា។

នៅក្នុងការពិភាក្សាតាមក្រុម ដែលទាក់ទងនឹងផលប៉ះពាល់នៃដើមក្លបយក្សនៅក្នុងតំបន់ស្ទួលទាំងបី អ្នកទទួលការសម្ភាសន៍ទាំងអស់ឆ្លើយថា វាបង្កផលប៉ះពាល់ខ្លាំងបំផុតចំពោះដីកសិកម្ម។ គេមានការយល់ដឹងតិចតួចប៉ុណ្ណោះអំពីផលប៉ះពាល់អេកូឡូស៊ី ជាពិសេសផលប៉ះពាល់ដែលទាក់ទងនឹងទីជម្រកសម្រាប់មច្ឆជាតិ។ អ្នកទទួលការសម្ភាសន៍មួយរូបនៅព្រែកទាល់បានពោលថា គាត់បានសង្កេតឃើញថា កាលណាមានដើមក្លបយក្សដុះច្រើន ពួកត្រីនានាដូចជាត្រីប្រា មិនចូលមករស់នៅទេ។ ដោយសារដើមក្លបយក្សបានសាយភាយទៅតាមច្រាំងទន្លេ វាបានធ្វើឱ្យធនធានជលផលធ្លាក់ចុះ។

យោងតាមអ្នកទទួលការសម្ភាសន៍ គេមានវិធីខុសៗគ្នាដើម្បីកំចាត់រុក្ខជាតិនេះ។ ប្រជាជននៅមូលដ្ឋានចំនួន៩៥% ដែលរងផលប៉ះពាល់ពីដើមក្លបយក្ស បានប្រើប្រាស់វិធីកំចាត់រុក្ខជាតិនេះ ដោយកាប់ឆ្ការ ឬដុត។ វិធីទាំងនេះពុំមានប្រសិទ្ធិភាពឡើយ និងត្រូវចំណាយច្រើន។ នេះគ្រាន់តែជាវិធីទប់ទល់បណ្ដោះអាសន្នប៉ុណ្ណោះ។ ដោយសារការដុត និងកាប់ឆ្ការមិនអាចទប់ស្កាត់ការលូតលាស់ឡើងវិញរបស់ដើមក្លបយក្សឡើយ វាថែមទាំងអាច ជំរុញជំណុះរុក្ខជាតិនេះថែមទៀតផង ដោយសារការធ្វើឱ្យបែកសំបកស្រោបការពារគ្រាប់។[21]

នៅតំបន់ស្ទួលស្ទឹងសែន អ្នកទទួលការសម្ភាសន៍មួយរូបបានពោលថា "ដើមក្លបយក្សលូតលាស់ និងសាយភាយយ៉ាងឆាប់រហ័សនៅក្រោយពេលដែលខ្ញុំកាប់ ឬដុតវា។ ឥឡូវនេះ ខ្ញុំដកវាទាំងឫស និងជំនួសដោយរុក្ខជាតិដទៃ ដូចជា "ត្រកួន"(Ipomeas aquatic) ដើម្បីទប់ស្កាត់ការដុះដើមក្លបយក្សឡើងវិញ"។

ទោះបីមានកិច្ចប្រឹងប្រែងទាំងនេះដើម្បីកំចាត់ដើមក្លបយក្សក៏ដោយ អ្នកឆ្លើយចំនួន៤៣%បានអះអាងអំពីការបោះបង់ចោលដីកសិកម្ម ដោយសារតែត្រូវចំណាយពេល និងប្រាក់កាសយ៉ាងច្រើនដើម្បីកំចាត់រុក្ខជាតិប្រភេទនេះ។

***អន្តរាគមន៍កម្មវិធី***

ក្រសួងបរិស្ថាន គ្រឹះស្ថានសិក្សា និងអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ បានទទួលស្គាល់ថាដើមក្លបយក្សបានបង្កការប៉ះពាល់ចំពោះបរិស្ថាន សេដ្ឋកិច្ចសង្គម និងរបរចិញ្ចឹមជីវិតនៅតាមមូលដ្ឋាន។ ការ

[21] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្ទួលស្ទឹងសែន ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ឆ្នាំ ២០១៣

ដោះស្រាយបញ្ហានេះគឺជាប្រការចាំបាច់ និងបន្ទាន់មួយ។ ក្នុងន័យនេះ ក្រសួងបរិស្ថានបានធ្វើការសិក្សាលក្ខខណ្ឌគោលមួយអំពី "ជីវៈចម្រុះ និងលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនៅមុនអន្តរាគមន៍គ្រប់គ្រងដើមក្លបយក្ស" នៅក្នុងទីតាំងសាកល្បងថ្នាក់ជាតិនៅតំបន់ស្នូលស្ទឹងសែន និងបានអនុម័តលើ"ផែនការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី"។ មានតែគ្រឹះស្ថានចំនួនពីរបានផ្តួចផ្តើមកម្មវិធីអន្តរាគមន៍មួយ។ អង្គការជីវិតសត្វស្លាបអន្តរជាតិ បានដាក់ឱ្យអនុវត្តគម្រោងសាកល្បងមួយនៅក្នុងទីតាំងមួយក្នុងខេត្តតាកែវ ដើម្បីកំចាត់ដើមក្លបយក្ស។ ពួកគេតាមដានគម្រោងនោះតាមរយៈការគាំទ្រហិរញ្ញវត្ថុដល់សហគមន៍ ដើម្បីប្រមូលយកគ្រាប់ក្លបយក្ស និងកាប់ផ្ការុក្ខជាតិនេះចោល។ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រោមកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាថ្នាក់តំបន់ បានចាត់ចែងការបណ្តុះបណ្តាលអំពីផលប៉ះពាល់មកលើប្រព័ន្ធអេកូឡូស៊ីជាពិសេសដើមក្លបយក្ស ដោយស្វែងយល់ពីគោលគំនិតនៅក្នុងការសិក្សាឯកសារដែលមានស្រាប់ និងការអនុវត្តជាក់ស្តែងអំពីវិធីក្នុងការកំចាត់ចោល។

*<u>ការចែករំលែកព័ត៌មាន និងបង្កើនការយល់ដឹង</u>*

ជាទូទៅ គេពុំសូវឃើញមានព័ត៌មានអំពីប្រភេទទន្រ្ទានរាតត្បាត និងរុក្ខជាតិបង្កគ្រោះថ្នាក់ផ្សេងៗឡើយ។ យោងតាមអ្នកផ្តល់ព័ត៌មានសំខាន់ៗមួយចំនួន មានការផ្សព្វផ្សាយព័ត៌មានក្នុងកម្រិតកំណត់អំពីប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា។ ប្រការចាំបាច់គឺត្រូវចាត់វិធានការដើម្បីទប់ស្កាត់ និងសកម្មភាពនានា តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ សិក្ខាសាលា និងការបណ្តុះបណ្តាលអំពីប្រភេទទន្រ្ទានរាតត្បាត។

នៅក្នុងតំបន់ស្នូលស្ទឹងសែន អ្នកឆ្លើយ៩៥% បានអះអាងថា ពួកគេពុំធ្លាប់បានឮពីកម្មវិធីទប់ស្កាត់ប្រភេទទន្រ្ទានរាតត្បាតឡើយ។ នៅតំបន់ព្រែកទាល់ និងចុងឃ្នាស គ្មានអ្នកឆ្លើយណាម្នាក់បានឮពីកម្មវិធីនេះឡើយ។

## ៦. ការសន្និដ្ឋាន

នៅកម្ពុជា ដើមក្លបយក្សត្រូវបានគេស្គាល់ថាជា "បន្លាក្លបយក្ស ឬ បន្លាអ៊ីយយ៉ាស់ ឬ បន្លាយួន" ដែលជា រុក្ខជាតិទន្រ្ទានរាតត្បាត និងអាចបង្កការគំរាមកំហែងចំពោះជីវៈចម្រុះ។

*ដើមក្លបយក្ស* ដែលជាពពួករុក្ខជាតិក្នុងអំបូរ leguminous អាចមានកំពស់រហូតដល់ ៦ ម៉ែត្រ។ វាមានប្រភពពីតំបន់ត្រូពិកក្នុងប្រទេសម៉ិចស៊ិក និងអាមេរិកកណ្តាល ប៉ុន្តែបានរាតត្បាត មកក្នុងទ្វីបអាហ្វ្រិកយ៉ាងហោចណាស់ ២០០ឆ្នាំមកហើយ។ រុក្ខជាតិនេះបានរាតត្បាតជាបន្តបន្ទាប់មកក្នុងតំបន់ដីសើម មាត់បឹង និងមាត់ទន្លេ និងតំបន់ទំនាបលិចទឹកនានា នៅទូទាំងអាហ្វ្រិក នៅក្នុងរយៈពេលយ៉ាងហោចណាស់ ៣០-៤០ ឆ្នាំចុងក្រោយនេះ និងបន្តសាយភាយ និងរាតត្បាតកន្លែងដទៃទៀត។[22]

ដើមក្លបយក្សបានរាតត្បាតនៅប្រទេសសកម្ពុជាអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ និងអាចឆ្លងមកពីប្រទេសជិតខាង។ រុក្ខជាតិនេះត្រូវបានចាត់ទុកជាប្រភេទរុក្ខជាតិព្រៃ។ ដើមក្លបយក្ស ត្រូវបាននាំចូលពីប្រទេសឥណ្ឌូនេស៊ី មកប្រទេសថៃ ប្រហែលជានៅឆ្នាំ១៩៤៧ សម្រាប់ទប់ស្កាត់ការហូរច្រោះបាក់ច្រាំងទន្លេសម្រាប់គ្របដំណាំថ្នាំជក់ និងសម្រាប់ផលិតជីធម្មជាតិ។[23] នៅឆ្នាំ១៩៤៩ ដើមក្លបយក្ស ត្រូវបានគេរកឃើញ

[22] IUCN
[23] Napompeth, 1983; Wara-Aswapati, 1983

នៅភាគខាងជើងនៃប្រទេសថៃ និងបានសាយភាយទៅក្នុងប្រទេសវៀតណាម ប្រហែលមុនឆ្នាំ១៩៧០។[24] បន្ទាប់មក រុក្ខជាតិនេះបានបន្តរាតត្បាតនៅក្នុងខេត្តឡុងអាន នៅឆ្នាំ១៩៧៩[25] និងបានបន្តរាតត្បាតមកប្រទេសកម្ពុជានៅឆ្នាំ១៩៨០[26] នៅក្នុងតំបន់បឹងទន្លេសាប ជាពិសេស នៅតាមដងទន្លេមេគង្គ ដែលគ្របដណ្តប់លើផ្ទៃដីជាច្រើនពាន់ហិចតានៃទំនាបលិចទឹក តំបន់ដីសើម និងដីដាំដំណាំដែលត្រូវបានបោះបង់ចោល។[27]

នៅក្នុងប្រមាណឆ្នាំ១៩៩៧ ដើមក្លបយក្សបានរាតត្បាតទៅក្នុងខេត្តជាច្រើននៃប្រទេសកម្ពុជា រួមមានខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្តាល កំពង់ឆ្នាំង កំពង់ធំ ពោធិសាត់ បាត់ដំបង សៀមរាប ព្រៃវែង ស្វាយរៀង តាកែវ និងកន្លែងខ្លះៗក្នុងខេត្តកំពង់ស្ពឺ។[28]

មានព័ត៌មានតិចតួចប៉ុណ្ណោះដែលបានចែករំលែក ទាក់ទងនឹងផលប៉ះពាល់នៃរុក្ខជាតិប្រភេទនេះ។

## ៧. អនុសាសន៍

យោងតាមក្របខ័ណ្ឌនៃការវាយតម្លៃនេះ គោលបំណងចុងក្រោយគឺលើកអនុសាសន៍សម្រាប់គាំទ្រដល់យុទ្ធសាស្ត្រផ្សព្វផ្សាយជាតិ និងអន្តរាគមន៍នានា ដើម្បីដោះស្រាយបញ្ហាប្រភេទទន្រ្ទានរាតត្បាត។ ផ្នែកនេះត្រូវបានចែកចេញជាសំណួរចំនួនពីរដូចតទៅៈ

- តើសាធារណជនមានការយល់ដឹងកម្រិតណាទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត និងតើមានកម្មវិធីអន្តរាគមន៍អ្វីខ្លះរួចមកហើយ?
- តើអាចបង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយជាតិបែបណា?

***អន្តរាគមន៍កម្មវិធី***

- គួរតែបានបង្កើតឡើងជាអាទិភាព ដែលរួមទាំង ការផ្តល់ព័ត៌មានដែលទាក់ទងនឹងប្រភេទទន្រ្ទានរាតត្បាត និងផលប៉ះពាល់របស់វា ដោយសារតែមានព័ត៌មានតិចតួចណាស់អំពីប្រភេទទន្រ្ទានរាតត្បាត និងរុក្ខជាតិបង្កគ្រោះថ្នាក់ផ្សេងៗ។
- គួរបង្កើតសារសំខាន់ៗ ករណីសិក្សា ឬ ល្បែង និងផ្សព្វផ្សាយតាមរយៈប្រព័ន្ធព័ត៌មានសាធារណៈ ដែលរួមទាំង ទូរទស្សន៍ វិទ្យុ សារព័ត៌មាន ផ្ទាំងផ្សព្វផ្សាយ វេបសាយ និងបណ្តាញព័ត៌មានសង្គម (ឧទាហរណ៍ ហ្វេសប៊ុក)។
- គួរបង្កើតកូនសៀវភៅ ផ្ទាំងព័ត៌មាន ដោយប្រើប្រាស់ភាសាងាយយល់ និងចែកចាយនៅតាមសហគមន៍ សាលារៀន ការិយាល័យស្រុក និងឃុំ។
- គួរចាត់ចែងឱ្យមានជាសិក្ខាសាលា ការប្រជុំផ្សព្វផ្សាយព័ត៌មាន ការប្រជុំ និងបណ្តាញចែករំលែកព័ត៌មាន។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ/អន្តរជាតិ ដែលកំពុងបំពេញការងារផ្សព្វផ្សាយ

[24] Thi et al., 2004
[25] Triet et al., 2004
[26] Vanna and Nang, 2003
[27] Samouth, 2004
[28] ការសិក្សាលក្ខខណ្ឌគោលអំពីជីវៈចម្រុះ និងសេដ្ឋកិច្ចសង្គម នៅមុនអន្តរាគមន៍គ្រប់គ្រងប្រក្លបយក្សនៅទីតាំងសាកល្បងជាតិក្នុងតំបន់ស្នួលស្ទឹងសែន ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ឆ្នាំ ២០១៣

អប់រំ អំពីប្រភេទទន្ទ្រានរាតត្បាតនៅក្នុងប្រទេសកម្ពុជា៕

# ឯកសារយោង


Beilfuss, R. 2007. Adaptive management of the invasive shrub Mimosa Pigra at Gorongosa National Park, Department of Scientific Service, December 2007

CBD (2002) Decision VI/23: Alien Species that Threaten Ecosystems, Habitats, and Species. The Hague, the Netherlands: Convention on Biological Diversity.

Chamroeun, K., Seang, T.P., Sophal, H., Hout, S.S. and Vuthy, H. (2001) An Investigation of the Impacts of Mimosa Pigra on Rice and fishery Productivity in Kandal Province, Cambodia.

McKenney, B. 2001, Economy and Environment: Case Studies in Cambodia, EEPSEA, International Development Research Centre (IDRC), Singapore

Chornesky, E.A. and J.M. Randall 2003, Threat of Invasive Alien Species to biological diversity: Setting a future course, Annals of the Missouri Botanic Garden

CNMC (Cambodia National Mekong Committee)/ Nedeco, 1998, sectorial studies "Environment in the Tonle Sap area, natural resources-based development strategy for the Tonle Sap area, Cambodia

Davies, J., Lopez, A. & Dubois, M. (2006) rapid inventory and assessment of wetland in Attapeu Province, Lao PDR

Grice. A. C. 2006, The Impact of Invasive plant species on the biodiversity of Australia rangelands Heard.

T.A., Mira, A. Chan. R. & Fichera, G. A. 2009, Application to release the tip weevil Temonerus debilis a potential biological control agent of the weed Mimosa Pigra

Hughes, NK, Burley, AL, King, SA and Downey, PO 2009 Monitoring manual for Bitou bush control and Native plant recovery, Department of Environment, Climate Change and Water, Sydney

JICA (1999), Cambodia Reconnaissance Survey Digital Data, Ministry of Public Works ad Transportation

Keskinen, M. 2003, Socio-Economic survey of the Tonle Sap Lake, Cambodia, Helsinki University of Technology

Kosal, M. 2004, "Biodiversity of Cambodia's Wetlands"

Lonsdale, W. M. 1992, The Biology of Mimosa Pigra, A guide to the Management of Mimosa Pigra

Mam, K., Muong S. & Prom N. (2011) initial findings of wetland and climate change impacts in lower Stung Sen wetland, Cambodia

Marko, M. 1999, Restoration and Reclamation Review: Controlling invasion of the toxic shrub (Mimosa Pigra) in tropical Australian Wetland

Mauremootoo, J. & Howard, G. 2006, pilot site management plan guidelines for the UNEP Project, Removing Barriers to Invasive Plant Management in Africa

McNeely J. A., Money H.A., Neville L.E., Schei P-J, and Waage J. (eds) (2001), Global Strategy on Invasive Alien Species, IUCN, Gland

Miththapala, S. (Ed.) (2007), Strategy for addressing issues of aquatic invasive alien species in the lower Mekong Basing

MoE, 2007, Tonle Sap information Quid, Live & learn Environmental Education

Napompeth, B. 1983, Threat and Distribution of Mimosa Pigra, Thailand

Oertzen, I. and J. Smith, 2001, Focus on Invasive Alien Species in Cambodia

Thi, N. T.L., Triet, T. Storrs, M., & Ashley, M. 2001, Determination suitable methods for the control of Mimosa Pigra in Tram Chim national Park, Vietnam, "Research and Management of Mimosa Pigra

Presnell, K. 2002, the Potential use of Mimosa Pigra as fuel for power generation, Centre for Energy Reearch, Charles Darwin University, Australia

Samouth, C. 2004, Mimosa Pigra infestation and current threat to wetlands and floodplains in Cambodia, Research and Management of Mimosa Pigra, CSIRO Entomology, Canberra, Australia

Storrs, M., Ashely, M., Tran Triet and Samouth Chan 2001, Towards the Development of Strategic Weed Management for the Lower Mekong basin, Mekong River Commission and Environment, Australia

Triet, T., Berzen, J., Choowaew, S., Engels, M., Persistent organic pollutants in wetlands of the Mekong Basin, U.S. Geological Survey, Reston Virginia

Vanna, S. & Nang, K. 2003, Cambodia, the Mimosa Pigra Report

Wara-Aswapati, O. 1983, Seed production and germination of Mimosa Pigra, L. Chiang Mai, Thailand

Weber, E. and Li, B. 2008, Plan Invasions, China, What is to be Expected in the Wake of Economic Development? Bio Science

Wingrave, S. 2002, Herbicides and their application for the control of mimosa in the Northern Territory, Australia